## សរុបព្រឹត្តការណ៍ប្រចាំថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០
## សម្រាប់ វីរុស COVID-19

### ១. រស្មីកម្ពុជា៖មន្ត្រី សុខាភិបាល: កុំ ជឿ ឱ្យសោះ ! ដួលសន្លប់ ឬ ដួល ស្លាប់ មិនមែនជា កូ រ៉ូ ណា វីរុស ទេ

រស្មីកម្ពុជា

ដំណឹងក្នុងប្រទេស | ក្នុងប្រទេស | សុខាភិបាល - អប់រំ

# មន្ត្រីសុខាភិបាល: កុំជឿឱ្យសោះ ! ដួលសន្លប់ ឬ ដួលស្លាប់ មិនមែនជា កូរ៉ូណាវីរុសទេ

March 5, 2020, 6:27 PM 75

ដោយ: មេសា/ភ្នំពេញ: ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាន នៅឯក្រសួងសុខាភិបាល នារសៀលថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០២០ នេះ លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការ និង ជាអ្នកនាំពាក្យក្រសួងសុខាភិបាល បានបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំសូមអំពាវនាវហើយ អំពាវនាវទៀត សូមសាធារណជន កុំជឿលើព័ត៌មានបំផ្លើស ព្រោះរហូតមកដល់ពេលនេះ យើងរកឃើញព័ត៌មានបំផ្លើស ឬ ព័ត៌មានក្លែងជាច្រើនករណី ដូចជាយករូបភាពមនុស្សដួលសន្លប់ ឬ ដួលស្លាប់ ជាដើម ។ បុគ្គលម្នាក់ នៅសុខៗ ដើរសុខៗ ក៏ដួលសន្លប់ ឬ ដួលស្លាប់នោះ សូមកុំជឿឱ្យសោះ ថាជាជំងឺ កូរ៉ូណាវីរុស ឬ COVID-19 ព្រោះជំងឺកូរ៉ូណាវីរុស ឬ COVID-19 មិនមានអាចបណ្តាលឱ្យដួលសន្លប់ ឬ ដួលស្លាប់បានទេ ! ដូច្នេះ ការដួលសន្លប់ ឬ ដល់ស្លាប់ ពិតជាមិនមែនជាជំងឺកូរ៉ូណាវីរុស ឬ COVID-19 ឡើយ ។




លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន ( កណ្តាល ) ថ្លែងនៅក្នុងសន្និសីទសារព័ត៌មាន ( រូប: មេសា )

បន្ថែមពីលើនេះ លោកសាស្ត្រាចារ្យ វ៉ាន់ ម៉ិច អ្នកឯកទេស និង ប្រធានផ្នែកជំងឺសួត នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងជាប្រធានសមាគមគ្រូពេទ្យសួតកម្ពុជា បានពន្យល់ថា ជំងឺកូរ៉ូណាវីរុស ឬ COVID-19 គឺជាប្រភេទមួយ នៃជំងឺរលាកសួត ហើយជំងឺរលាកសួតទាំងអស់ ដោយរួមទាំង COVID-19 ផង បន្ទាប់ពីឆ្លងហើយ អាចក្នុងរយៈពេល ៣ ថ្ងៃ ៧ ថ្ងៃ ទៅ ១៤ ថ្ងៃ ទើបបញ្ចេញអាការ ដូចជា ក្តៅខ្លួនលើសពី ៣៨ អង្សា ក្អកស្ងួត ឈឺ ក ហត់ ពិបាកដកដង្ហើម ដែលអាការទាំងនេះ អាចឱ្យគេមើលឃើញបាន ។ បន្ទាប់មក បើគ្មានការព្យាបាលឱ្យបានត្រឹមត្រូវទេ វានឹងវិវឌ្ឍន៍ទៅជាធ្ងន់ធ្ងរ បន្ទាប់មកទើបអាចឈានដល់ស្លាប់ ពោលគឺមិនមែននៅសុខៗ ដើរសុខៗ ឬ អង្គុយសុខៗ ដួលសន្លប់ ឬ ដួលស្លាប់ភ្លាមៗទេ ។

លោកស្រីសាស្ត្រាចារ្យ រស់ សីហា ឯកទេស និង ប្រធានផ្នែក សរសៃប្រសាទ នៃ មន្ទីរពេទ្យកាល់ម៉ែត បានពន្យល់ពីមូលហេតុនាំឱ្យមនុស្សដួលសន្លប់ថា មូលហេតុ ដួលសន្លប់មានច្រើន ដូចជា ប្រព័ន្ធខួរក្បាលលែងមានទំនាក់ទំនងខាងក្រៅ ឬ លែងដំណើរការ , សរសៃឈាមបេះដូង , សរសៃឈាមខួរក្បាល , ជំងឺឆ្កួតជ្រូក ជាដើម ។ ដូច្នេះ នៅពេលឃើញនរណាម្នាក់ដួលសន្លប់នោះ ការដែលយើងនាំគ្នាខ្លាច ហើយរត់គេច គឺជារឿងផ្ទុយស្រឡះ ព្រោះអ្នកទាំងនោះ មិនមែនជាអ្នកជំងឺ COVID-19 ប៉ុន្តែពួកគេគឺជាអ្នកជំងឺដែលត្រូវការការជួយជាបន្ទាន់ ហើយប្រសិនបើមិនបានជួយទាន់ពេលទេនោះ ពួកគេអាចនឹងស្លាប់ ហេតុនេះ យើងត្រូវតែពិចារណាឡើងវិញ ។

ក្នុងសន្និសីទនោះដែរ លោកស្រី Philomena Raftery មន្ត្រីបច្ចេកទេស នៃ អង្គការសុខភាពពិភពលោកប្រចាំកម្ពុជា បានយល់ស្រប ទៅនឹងការលើកឡើងរបស់អ្នកជំនាញទាំងឡាយពីខាងដើមមកនោះ ដោយលោកស្រីអះអាងថា រហូតមកដល់ពេលនេះពិភពលោកមិនទាន់រកឃើញជំងឺរលាកសួតណាមួយ ដោយរួមទាំង COVID-19 ផង អាចបណ្តាលឱ្យមនុស្សដួលសន្លប់ ឬ ដួលស្លាប់ភ្លាមៗឡើយ ។

**តើកម្ពុជាបានលាក់ ឬ បិទខ្ទប់ព័ត៌មាន COVID-19 មែនឬ ?**

នៅពេលឆ្លើយនឹងសំណួរដែលកន្លងមកមានអ្នកខ្លះ លើកឡើងថា ត្រូវបានរកឃើញករណីCOVID-19 នៅទីនេះ ទីនោះ មន្ទីរពេទ្យនេះ មន្ទីរពេទ្យនោះ ជាដើម ប៉ុន្តែត្រូវបានមន្ត្រីលាក់ ឬ បិទខ្ទប់ព័ត៌មានទាំងនោះ មិនឱ្យផ្សាយចេញទៅ ដោយហេតុណាមួយ ដូចជា ដើម្បី ការពារកិត្តិយសមុខមាត់រដ្ឋាភិបាលជាដើម លោកស្រី វេជ្ជបណ្ឌិត ឱ វណ្ណឌីន បានលើកឧទាហរណ៍ថា ករណីជនជាតិ ចិន ម្នាក់នៅខេត្តព្រះសីហនុ ថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់លំដាប់ថ្នាក់បានខិតខំយ៉ាងសកម្មទាំងយប់ទាំងថ្ងៃ នៅពេលដឹងច្បាស់ថា បុរសម្នាក់នោះ មាន COVID-19 ភ្លាម ក្រសួង និង អ្នកពាក់ព័ន្ធក៏ចាត់វិធានការគ្រប់យ៉ាង រួចហើយធ្វើសន្និសីទសារព័ត៌មានភ្លាម ដោយគ្មានពន្យឺតពន្យារ ។ ក្នុងន័យនេះ ប្រសិនបើក្រសួង ឬ កម្ពុជា មានបំណងលាក់ ឬ បិទខ្ទប់ព័ត៌មានមែននោះ ម៉្លេះលាក់ ឬ បិទខ្ទប់តាំងពីពេលនោះមកម៉្លេះ ។

លោកស្រី ឱ វណ្ណឌីន បន្ថែមថា ដូច្នេះក្រសួងពិតជាមិនមានអ្វីត្រូវលាក់ ឬ បិទខ្ទប់ជាដាច់ខាត ផ្ទុយទៅវិញ

ក្រសួងសុខាភិបាល តែងតែខិតខំគ្រប់បែបយ៉ាង ដើម្បី ផ្តល់ព័ត៌មានគ្រប់យ៉ាងទៅសាធារណជនឱ្យលឿន និង សុក្រឹតបំផុត ។

ជាថ្មីម្តងទៀត លោកស្រី ឱ វណ្ណឌីន បញ្ជាក់ថា រហូតមកដល់ពេលនេះ កម្ពុជា ដែលប្រកាន់ខ្ជាប់នូវគោលការណ៍ស្តង់ដារអន្តរជាតិ របស់អង្គការសុខភាពពិភពលោក ថែមទាំងដោយមានកិច្ចសហការយ៉ាងជិតដល់ និង ហ្មត់ចត់ ពីអង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាម៉េរិក និង វិទ្យាស្ថានប៉ាស្ទ័រ ដែលជាស្ថាប័នអន្តរជាតិ រហូតមកដល់ពេលនេះ បានធ្វើតេស្តយ៉ាងហ្មត់ចត់ លើសំណាក ជនសង្ស័យចំនួន ១៤៥ នាក់ ដោយលទ្ធផល “ **អវិជ្ជមានទាំងអស់** “ លើកលែងតែជនជាតិចិន ម្នាក់នៅខេត្តព្រះសីហនុ ដែលត្រូវបានព្យាបាលជាសះស្បើយរួចរាល់ហើយ ។

នៅពេលសួរថា ពេលនេះតើសាធារណជនកម្ពុជា ត្រូវធ្វើអ្វី និង មិនត្រូវធ្វើអ្វី លោកស្រី ឱ វណ្ណឌីន បានឆ្លើយថា ទី ១ ត្រូវការពារខ្លួនដោយមិនអាចធ្វេសប្រហែសបានឡើយ ហើយការការពារខ្លួននោះ ដូចជាពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ និង ឧស្សាហ៍លាងដៃ ជាដើម ដែលក្រសួងបានផ្សព្វផ្សាយជូនជាច្រើនលើកមកហើយ , ទី ២ កុំភ័យហួសហេតុពេក នាំឱ្យជនខិលខូចបោកប្រាស់បាន ។

ដោយតែងតែអះអាងដដែលជាដដែលថា ក្រសួង និង ស្ថាប័នពាក់ព័ន្ធតែងតែទប់ស្កាត់ តាមដាន ស្រាវជ្រាវរារក យ៉ាងសកម្ម ចំពោះវត្តមាន COVID-19 ក៏ពិតមែន ប៉ុន្តែ ក្នុងលោកនេះ មិនទាន់មានប្រព័ន្ធការពារណាមួយមាន ប្រសិទ្ធភាព ១០០ ភាគរយទេ ជាក់ស្តែងដូចជានៅប្រទេស កូរ៉េខាងត្បូង អ៊ីតាលី និង សហរដ្ឋអាម៉េរិក ជាដើម ដែល ប្រព័ន្ធការពាររបស់ប្រទេសទាំងនោះ សុទ្ធតែត្រូវបាន ពិភពលោកទទួលស្គាល់ថា ខ្លាំងពូកែ ប៉ុន្តែប្រទេស ទាំងនោះ នៅតែអាចឆ្លង COVID-19 នេះបាន ។

អង្គសន្និសីទ ក៏បានលើកឡើងផងដែរ ចំពោះព័ត៌មានដែល ត្រូវបានបង្ហោះតាមបណ្តាញសង្គម ហ្វេសប៊ុក ដូជាមនុស្ស ដួលសន្លប់នោះ មានព័ត៌មានខ្លះ ត្រូវបានកាត់ ត ក្នុង បំណងអាក្រក់ ដោយសារត្រូវបានរកឃើញថា បុគ្គលដែល បានដួលសន្លប់នោះ គឺសន្លប់តាំងពីច្រើនខែមកហើយ ទើបតែយកមកកាត់ ត និង បង្ហោះនាពេលនេះ ខណៈរូបខ្លះ ត្រូវគេយកទៅច្នៃជាព័ត៌មានខុសៗគ្នា ហើយបង្ហោះ ធ្វើឱ្យ សង្គមភ័យខ្លាច ។

ជាថ្មីម្តងទៀត លោកស្រី ឱ វណ្ណឌីន បានអះអាងថា កម្ពុជា តែងតែស្រាវជ្រាវ តាមដានយ៉ាងសកម្ម ដោយមានទាំង

## ២. រស្មីកម្ពុជា៖ករណីស្ត្រីម្នាក់ដួលសន្លប់នៅអគារ កាណាឌីយ៉ាមិនមែនដោយសារជំងឺ Covid-19 ទេ ជាករណីខ្យល់គ

រស្មីកម្ពុជា

ដំណឹងក្នុងប្រទេស | សន្តិសុខ | ក្នុងប្រទេស | សង្គម

# ករណីស្ត្រីម្នាក់ដួលសន្លប់នៅអគារ កាណាឌីយ៉ាមិនមែនដោយសារជំងឺ Covid-19 ទេ ជាករណីខ្យល់គរ ធម្មតា

March 5, 2020, 3:13 PM

97

*ដោយ:រ៉ាម៉ន/ភ្នំពេញ* ៖ លោក ម៉េត មាសភក្តី អ្នកនាំពាក្យសាលារាជធានីភ្នំពេញបានថ្លែងជូនដំណឹងដល់សាធារណៈជនឱ្យបានដឹងថា៖ មានករណីស្ត្រីម្នាក់វិលមុខដួលសន្លប់នៅអគារកាណាឌីយ៉ាកាលពីម្សិលមិញ មិនមែនដោយសារជំងឺ Covid-19 ទេ ជាករណីខ្យល់គរធម្មតា ហើយបច្ចុប្បន្នកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត។

លោក ម៉េត មាសភក្តី បានបញ្ជាក់ទៀតថា៖ស្ត្រីវិលមុខខ្យល់គរនោះមានឈ្មោះ សំ សុវណ្ណចរិយា ជាបុគ្គលិកបម្រើការងារនៅធនាគារកាណាឌីយ៉ា បានដួលសន្លប់នៅក្នុងបន្ទប់ទឹកនៃអគារកាណាឌីយ៉ា។

គួបញ្ជាក់ថា នៅម៉ោង៣រសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០នេះ ក្រសួងសុខាភិបាល នឹងរៀបចំសន្និសីទសារព័ត៌មានមួយ ដើម្បីបំភ្លឺសំណួរពាក់ព័ន្ធនឹងជំងឺ និងការធ្វើតេស្ត កូវីដ ១៩ (Covid-19) និងការដួលសន្លប់ ឬដួលស្លាប់ ដែលមហាជននាំគ្នាសង្ស័យថា ករណី ដួលសន្លប់ ឬ ដួលស្លាប់នោះដោយសារជំងឺ Covid-19៕/B

## ៣. រស្មីកម្ពុជា៖ វៀតណាម ដាក់ មនុស្ស ជាង ៦0 នាក់ នៅ ដាច់ ពី គេ ដោយ ខ្លាច ឆ្លង វីរុស ពាក់ព័ន្ធ នឹង ជនជាតិ ជប៉ុន ចេញពី កម្ពុជា



ដំណឹងអន្តរជាតិ

# វៀតណាមដាក់មនុស្សជាង៦០នាក់នៅដាច់ពីគេដោយខ្លាចឆ្លងវីរុស ពាក់ព័ន្ធនឹងជនជាតិជប៉ុនចេញពីកម្ពុជា

March 5, 2020, 2:53 PM

102

សមាជិកបំរើការក្នុងយន្តហោះ១២នាក់និងអ្នកដំណើរ៥១នាក់ក្នុងចំណោមអ្នកដំណើរ៧៣នាក់នៅក្នុងយន្តហោះមួយនៃក្រុមហ៊ុនអាកាសចរណ៍វៀតណាម(Vietnam Airlines) ដែលចេញពីទីក្រុងណាហ្គោយ៉ា ប្រទេសជប៉ុន មកកាន់ទីក្រុងហូជីមីញ ប្រទេសវៀតណាម ត្រូវបានដាក់នៅដាច់ពីគេ ដោយសារតែខ្លាចពួកគឺឆ្លងកូរ៉ូណាវីរុសពីអ្នកដំណើរជប៉ុនម្នាក់។

គេហទំព័ររបស់រដ្ឋាភិបាលវៀតណាម ដែលបានយោងតាមក្រសួងសុខាភិបាលរបស់ខ្លួន បាននិយាយនៅថ្ងៃ០៥មីនាថាអ្នកដំណើរជនជាតិជប៉ុនម្នាក់ត្រូវបានពិនិត្យរកឃើញកូរ៉ូណាវីរុសCovid-19ក្រោយចុះនៅអាកាសយានដ្ឋានអន្តរជាតិChubu Centrair ក្នុងទីក្រុងណាហ្គោយ៉ា កាលពីថ្ងៃពុធទី៤មីនា ក្រោយបង្ហាញរោគសញ្ញាក្តៅខ្លួន។

អ្នកដំណើរ៥១នាក់ក្នុងជើងហោះហើរ VN341បានចុះនៅអាកាសយានដ្ឋានក្នុងទីក្រុងហូជីមីញកាលពីថ្ងៃពុធ ។ពួកត្រូវដាក់នៅដាច់ពីគេ នៅពេលអ្នកដំណើរ២២នាក់ទៀតសុទ្ធតែជនជាតិជប៉ុន ត្រូវបានអនុញ្ញាតអោយតជើងហោះហើរបន្តទៅទៀត។នេះបើតាមរដ្ឋាភិបាលវៀតណាម។

សន្តិសុខ២នាក់ និងនិយោជិត៦នាក់នៅក្នុងបន្ទប់មួយនៃអាកាសយានដ្ឋាន តាន់ សុន ញឹត ក៏ត្រូវដាក់នៅដាច់ពីគេ

បន្ទាប់ពីបានទាក់ទងជិតស្និទ្ធនឹងអ្នកដំណើរជប៉ុនដែលឈឺ។

បើតាមសារព័ត៌មានវៀតណាម អ្នកដំណើរជប៉ុនដែលឆ្លង Covid-19នេះ បានជិះយន្តហោះវៀតណាមកាលពីថ្ងៃអង្គារ ពីខេត្តសៀមរាប ប្រទេសកម្ពុជាទៅកាន់ទីក្រុងហូជីមីញ មុនតជើងយន្តហោះទៅកាន់ជប៉ុន។

អនុរដ្ឋមន្ត្រីសុខាភិបាលវៀតណាម ក៏បានបញ្ជាអោយអាជ្ញាធរក្រុងហូជីមីញតាមរកមនុស្ស៥នាក់ រួមមានជនបរទេស៤នាក់ ដែលបានធ្វើដំណើរពីសៀមរាមមកក្រុងហូជីមីញ ជាមួយអ្នកជម្ងឺជនជាតិជប៉ុន នេះបើតាមកាសែតយុវជន។ប្រែសម្រួល៖*វាសនា*

## ៤. រស្មីកម្ពុជា៖ កូរ៉ូណា វីរុស អាច រស់នៅ លើ វត្ថុ គ្មាន ជីវិត និង ឆ្លងទៅ មនុស្ស ដូច ការចម្លង ពី អ្នក ជម្ងឺ ដែរ

សុខភាព-អប់រំផ្លូវភេទ | សុខភាពទូទៅ | ដំណឹងអន្តរជាតិ

### កូរ៉ូណាវីរុស អាចរស់នៅលើវត្ថុគ្មានជីវិតនិងឆ្លងទៅមនុស្ស ដូចការចម្លងពីអ្នកជម្ងឺដែរ

March 5, 2020, 12:22 PM 419

ការសិក្សាថ្មីមួយនៅសិង្ហបុរី ដែលត្រូវបានចេញផ្សាយកាលពីថ្ងៃពុធទី០៤មីនា បង្ហាញថា អ្នកជម្ងឺកូរ៉ូណាវីរុស Covid-19 បានធ្វើអោយបន្ទប់ដេកនិងបន្ទប់ទឹករបស់គេប្រឡាក់ប្រឡូសទៅដោយវីរុស ដែលវាបង្ហាញថា ចាំបាច់ត្រូវមានសម្អាតធ្វើអនាម័យកន្លែងអ្នកជម្ងឺប៉ះពាល់ញឹកញាប់បំផុតដូចជាបន្ទប់ទឹកនិងចានបង្គន់ជាដើម។

តែទោះជាយ៉ាងណាវីរុសនេះអាចសម្លាប់ចោលដោយការលាងសម្អាតផ្ទៃដែលអ្នកជម្ងឺប៉ះពាល់២ដងក្នុងមួយថ្ងៃនិងលាងឥដ្ឋម្តងក្នុងមួយថ្ងៃ ដោយប្រើថ្នាំសម្លាប់មេរោគ។

ឯកសារសិក្សាស្រាវជ្រាវនេះត្រូវបានចុះផ្សាយក្នុងសារព័ត៌មាននៃសមាគមវេជ្ជសាស្ត្រអាម៉េរិក(JAMA) ។វាត្រូវបានបង្ហាញឡើងក្រោយពីបុគ្គលិកពេទ្យចិនជាច្រើននិងអ្នកជម្ងឺផ្សេងទៀតបានឆ្លងវីរុសនេះនៅក្នុងមន្ទីរពេទ្យ ទោះជាពួកគេបានប្រើឧបករណ៍ការពារវីរុសក្នុងពេលព្យាបាលអ្នកជម្ងឺក្តី។

ការរកឃើញនេះនាំអោយពួកអ្នកវិទ្យាសាស្ត្រជឿថា ក្រៅពីឆ្លងតាមរយៈក្អក កណ្តាស់និងប៉ះពាល់អ្នកជម្ងឺ បរិយាកាសជុំវិញដែលជាប់វីរុសនេះក៏ជាកត្តាសំខាន់មួយក្នុងការចម្លងកូរ៉ូណាវីរុស តែវិសាលភាពរបស់វានៅមិនទាន់ច្បាស់។

ពួកអ្នកសិក្សាស្រាវជ្រាវនៅ មជ្ឈមណ្ឌលជាតិសំរាប់ជម្ងឺឆ្លង

និងមន្ទីរពិសោធន៍ជាតិសិង្ហបុរី បានពិនិត្យលើអ្នកជម្ងឺ៣នាក់ដែលត្រូវបានបង្ខាំងទុកក្នុងបន្ទប់ផ្សេងគ្នារវាងចុងខែមករានិងដើមខែកុម្ភៈ។ពួកគេប្រមូលសំណាកមកពីបន្ទប់ទាំងនោះ ទាំងមុននិងនៅក្រោយការសម្អាតសម្លាប់មេរោគ។ ពួកគេបានរកឃើញថានៅក្នុងបន្ទប់ដែលមិនមានការសម្អាតសម្លាប់មេរោគ វីរុសមាននៅលើកៅអី កម្រាលពូក កញ្ចក់បង្អួច កម្រាលឥដ្ឋនិងកុងតាក់បិទបើកភ្លើង។

នៅក្នុងបន្ទប់ទឹក គេរកឃើញវីរុសនៅលើចានលុបលាងមុខត្រចៀកទ្វារ និងចានបង្គន់។

ចំណែកបន្ទប់ដែលត្រូវបានធ្វើអនាម័យសម្លាប់មេរោគរួចសំណាកចេញពីបន្ទប់នោះមិនត្រូវបានរកឃើញកូរ៉ូណាវីរុសទេ។

កាលពីពេលថ្មីៗមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជម្ងឺអាម៉េរិកក៏បាននិយាយថាកូរ៉ូណាវីរុសអាចចម្លងពីផ្ទៃនៃវត្ថុដែលមានវីរុស នៅពេលមនុស្សម្នាក់ប៉ះពាល់ផ្ទៃនៃវត្ថុនោះ រួចយកដៃទៅប៉ះមាត់ ច្រមុះឬភ្នែកខ្លួនឯង។

យោងតាមទីភ្នាក់ងារសារព័ត៌មានរ៉យទ័រ និងកាសែតស្រេ្តតថៃមស៍ ការវិភាគលើការសិក្សាចំនួន២២មុនៗអំពីកូរ៉ូណាវីរុសស្រដៀងគ្នា រួមមានវីរុសSarsនិងMersបានសន្និដ្ឋានថា កូរ៉ូណាវីរុសក្នុងខ្លួនមនុស្សនៅតែអាចចម្លងនៅលើផ្ទៃវត្ថុគ្មានជីវិតបានទៅដល់៩ថ្ងៃឯណោះ នៅក្នុងសីតុណ្ហភាពក្នុងបន្ទប់។

តែ វាអាចធ្វើអោយងាប់ឬសន្លប់លែងអាចចម្លងដោយការប្រើថ្នាំសម្លាប់មេរោគធម្មតា និងក៏អាចងាប់នៅក្នុងសីតុណ្ហភាពខ្ពស់ ទោះជាយ៉ាងណាគេនៅមិនទាន់ប្រាដកថា កូរ៉ូណាវីរុសថ្មីឈ្មោះCovid-19បច្ចុប្បន្ននេះដូចគ្នានឹងកូរ៉ូណាវីរុសSarsនិងMersដែរឬអត់។




សូមបញ្ជាក់ថា វីរុស ដែលមានឈ្មោះផ្លូវការថា Covid-19 ដែលបានបង្ហាញវត្តមានមុនគេនៅខេត្តហ៊ូប៉ី ប្រទេសចិនកាលពីខែធ្នូឆ្នាំ២០១៩ បានចម្លងទៅមនុស្សជាង៩៥.០០០នាក់នៅក្នុងតំបន់និងប្រទេសចំនួន៨១ និងសម្លាប់មនុស្សជាង៣.២០០នាក់។ប្រែសម្រួលៈ*វាសនា*

## ៥. រស្មីកម្ពុជា៖ប៊ីលហ្គេតហៅវីរុសកូរ៉ូណាជាជំងឺឆ្លង "កើតឡើងរាល់មួយសតវត្សរ៍ម្តង"

កម្សាន្ត

# ប៊ីលហ្គេតហៅវីរុសកូរ៉ូណាជាជំងឺឆ្លង "កើតឡើងរាល់មួយសតវត្សរ៍ម្តង"

March 5, 2020, 3:23 PM

90

មហាសេដ្ឋីសប្បុរសធម៌ លោកប៊ីលហ្គេតកាលពីថ្ងៃទី ២៨ ខែកុម្ភៈបានជំរុញឱ្យប្រទេសអ្នកមានស្តុកស្តម្ភជួយប្រទេសដែលមានប្រាក់ចំណូលទាបនិងមធ្យមពង្រឹងប្រព័ន្ធសុខភាពរបស់ពួកគេ ដោយសង្ឃឹមថានឹងពន្យឺតការឆ្លងរាលដាលនៃវីរុសកូរ៉ូណា ដែលលោកហ្គេតនិយាយថាបានចាប់ផ្តើមមានលក្ខណៈដូចជាមេរោគឆ្លង "កើតឡើងរាល់មួយសតវត្សរ៍ម្តង"។

លោកហ្គេត អតីតប្រធាននិងជានាយកប្រតិបត្តិនៃក្រុមហ៊ុន Microsoft Corp បានសរសេរក្នុងបទវិចារណកថាមួយនៅក្នុងទស្សនាវដ្តីវេជ្ជសាស្ត្រ New England Journal ថា "តាមរយៈការជួយប្រទេសក្នុងទ្វីបអាហ្វ្រិកនិងអាស៊ីខាងត្បូងត្រៀមខ្លួនជាស្រេចពីឥឡូវទៅ យើងអាចជួយសង្គ្រោះអាយុជីវិតនិងជួយពន្យឺតការឆ្លងរាលដាលនៃវីរុសកូរ៉ូណាពាសពេញពិភពលោក"។

វីរុសកូរ៉ូណាដែលកើតឡើងដំបូងនៅក្នុងប្រទេសចិននិងឥឡូវនេះបានរាលដាលដល់ប្រទេសជាង៨០គឺពិបាកបញ្ឈប់ជាងមេរោគស្រដៀងគ្នានេះ ដូចជា ជំងឺមីស និង ជំងឺសា។

អង្គការមូល Bill and Melinda Gates Foundation បានសន្យាបរិច្ចាគប្រាក់ ១០០ លានដុល្លារដើម្បីប្រយុទ្ធនឹងវីរុសកូរ៉ូណា។ ដោយ៖ កញ្ញាដាលីស

## ៦. កោះសន្តិភាព៖ស្ថានទូតជប៉ុនបញ្ជាក់លម្អិតនៃការធ្វើដំណើររបស់ជនជាតជប៉ុនពីសៀមរាបដែលមាន COVID-19

កោះសន្តិភាព KOH SANTEPHEAP MEDIA




# ស្ថានទូតជប៉ុនបញ្ជាក់លម្អិតនៃការធ្វើដំណើររបស់ជនជាតិជប៉ុនពីសៀមរាបដែលមាន COVID-19 Chat

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០
ម៉ោង ១៧:៤៨
គុច ណាវ៉ែន

Share

Like 1.6K

ស្ថានទូតជប៉ុន ទទួលជ្រាបព័ត៌មានទាក់ទងនឹងបុរសជនជាតិជប៉ុនដែលមានផ្ទុកមេរោគកូរ៉ូណាណូវែលថ្មី បានធ្វើដំណើរចេញពីកម្ពុជាទៅកាន់ប្រទេសជប៉ុន។ អាស្រ័យហេតុដូច្នេះ ស្ថានទូតជប៉ុន សូមចែករំលែក សេចក្តីប្រកាសព័ត៌មានពីក្រសួងសុខាភិបាលជប៉ុនដូចភ្ជាប់ខាងក្រោម។

ស្ថានទូតជប៉ុន នឹងបន្តសហប្រតិបត្តិការជាមួយអាជ្ញាធរកម្ពុជាពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណា ណូវែល(COVID-19)។ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលជប៉ុន នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០(ការបកប្រែក្រៅផ្លូវការ) ថ្ងៃទី៤ ខែមីនា ក្រសួងសុខាភិបាលជប៉ុនបានរកឃើញអ្នកជម្ងឺម្នាក់ដែលមានផ្ទុកមេរោគកូរ៉ូណាណូវែល (COVID-19) ក្នុងចំណោមបណ្តាអ្នកដំណើរផ្សេងៗទៀតដែលបានមកដល់អាកាសយានដ្ឋានអន្តរជាតិជូបឺ(ក្រុងណាហ្គូយ៉ា នៃប្រទេសជប៉ុន)។



តាមរយៈការវិនិច្ឆ័យរបស់អ្នកជម្ងឺ ដោយការធ្វើតេស្ត PCR នៅសាខាស្ថានីយត្រួតពិនិត្យអាកាសយានដ្ឋានជូប៊ី នៃស្ថានីយត្រួតពិនិត្យណាហ្គូយា លទ្ធផលបានបង្ហាញពីសញ្ញាវិជ្ជមាននៃការផ្ទុកមានមេរោគកូរ៉ូណាណូវែល (COVID-19) នៅវេលាម៉ោង ១៣:៣០នាទី នៅថ្ងៃទី៤ ខែមីនា ហើយបន្ទាប់មកអ្នកជម្ងឺត្រូវបានបញ្ជូនទៅកាន់ វិទ្យាស្ថានវេជ្ជសាស្ត្រក្នុងខេត្តអៃឈី ដោយដាក់ឲ្យនៅដោយឡែក។ ក្រសួងសុខាភិបាលជប៉ុន នឹងធ្វើការស្រាវជ្រាវយ៉ាងសស្រាក់សស្រាំលើមេរោគរាតត្បាតមួយនេះ ព្រមទាំងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក និងស្ថាប័នពាក់ព័ន្ធលើការវាយតម្លៃហានិភ័យ។

ព័ត៌មានរបស់អ្នកជម្ងឺ១. អាយុ៖ ខ្ទង់៤០ឆ្នាំ ២. ភេទ៖ ប្រុស ៣. ស្នាក់នៅ៖ ខេត្តមីអិ ៤. ប្រវត្តិនៃការធ្វើដំណើរថ្ងៃទី១៦ ខែកុម្ភៈ៖ ចាកចេញពីប្រទេសជប៉ុន ថ្ងៃទី១៦ ខែកុម្ភៈ៖ ធ្វើដំណើរទៅកាន់ព្រះរាជាណាចក្រកម្ពុជា ឆ្លងកាត់តាមប្រទេសវៀតណាម ថ្ងៃទី២១ ខែកុម្ភៈ៖ ធ្វើដំណើរទៅកាន់ប្រទេសហ្វីលីពីន ថ្ងៃទី២៨ ខែកុម្ភៈ៖ ធ្វើដំណើរទៅកាន់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៤ ខែមីនា៖ ត្រលប់មកប្រទេសជប៉ុនវិញ ឆ្លងកាត់តាមប្រទេសវៀតណាម ៥. អាការៈសុខភាព ថ្ងៃទី២១ ខែកុម្ភៈ៖ ក្តៅខ្លួន ថ្ងៃទី២ ខែមីនា៖ ក្អកស្លេះ និងតឹងទ្រូង ថ្ងៃទី៣ ខែមីនា៖ ទៅពិគ្រោះនៅមន្ទីរពេទ្យ និងត្រូវបានណែនាំឲ្យបន្តការតាមដាន ថ្ងៃទី៤ ខែមីនា៖ ទៅពិគ្រោះនៅបន្ទប់ពិគ្រោះយោបល់សុខភាពនៅស្ថានីយត្រួតពិនិត្យនៃអាកាសយានដ្ឋានជូប៊ី ដោយសារតែមានអាការៈតឹងទ្រូង និងក្អក បន្ទប់ពិគ្រោះយោបល់សុខភាព បានរកឃើញថាមានបញ្ហាផ្លូវដង្ហើម និងការឈឺចុកចាប់ជុំវិញផ្នែកទ្រូង ។

វេជ្ជបណ្ឌិតវេជ្ជសាស្ត្រ បានផ្តល់ប្រឹក្សា និងលើកឡើងពីលទ្ធភាពដែល អាចមានផ្ទុកមេរោគកូរ៉ូណា ណូវែល (COVID-19) ហើយស្ថានីយត្រួតពិនិត្យ បានធ្វើតេស្តវិនិច្ឆ័យ PCR។

## ៧. កោះសន្តិភាព៖រកឃើញ ៤៤នាក់ ប៉ះពាល់ ដោយ ផ្ទាល់ និង ប្រយោលជាមួយជនជាតិ ជប៉ុន មាន Co vid - 19

កោះសន្តិភាព
KOH SANTEPHEAP MEDIA




# រកឃើញ៤៤នាក់ ប៉ះពាល់ដោយផ្ទាល់និងប្រយោលជាមួយជនជាតិជប៉ុនមានCovid-19

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០
ម៉ោង ១៧:០០
គុច ណារ៉េន

Share

Like 1.9K

រាជធានីភ្នំពេញ ៖ យោងតាមនាយកដ្ឋានប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា ក្រោយពីទទួលបានព័ត៌មានថា ជនជាតិជប៉ុនមានផ្ទុកមេរោគ Covid-19, ក្រុមមន្ត្រីសុខាភិបាលថ្នាក់ជាតិ ថ្នាក់ខេត្ត និងអាជ្ញាធរខេត្តសៀមរាប កំពុងធ្វើការលើករណីនេះដោយតម្លាភាពបំផុត និធ្វេ◌ីការប្រកបដោយភាពត្រឹមត្រូវបំផុត ទៅតាមនីតិវិធីរបស់អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រ ។

យេ◌ីងបានរកឃេ◌ីញអ្នកប៉ះពាល់ផ្ទាល់៤នាក់ និងប្រមាណ៤០នាក់ប៉ះពាល់ដោយប្រយោល ដែលតម្រូវឱ្យគាត់នៅដោយឡែកពីគេចំនួន១៤ថ្ងៃ និងតាមដានសុខភាព ។ បេ◌ីមានចេញរោគសញ្ញាត្រូវយកវត្ថុវិភាគជាបន្ទាន់ រហូតពេលនេះពួកគាត់ពុំទាន់មានរោគសញ្ញានៅឡេ◌ីយទេ ។

សូមបញ្ជាក់ថា ជនជាតិជប៉ុននេះ គាត់ជាអ្នកធុរកិច្ចគាត់បានធ្វើដំណើរជាបន្តបន្ទាប់ក្នុងរយៈពេលខ្លីពី ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសហ្វីលីពីន ប្រទេសកម្ពុជា បន្ទាប់មកទៅវៀតណាម និងត្រលប់ចូលប្រទេសជប៉ុនវិញ ហើយរកឃើញវិជ្ជមានCOVID-19 នៅទីនោះ ។ រហូតដល់ម៉ោង៨រសៀលថ្ងៃទី ៥ មីនា ២០២០ នៅមិនទាន់កឃើញករណីថ្មីនៅឡើយទេ ។

## ៨. កោះសន្តិភាពៈតើ អាកា រៈឬ សញ្ញា អ្វីខ្លះ ដែល សង្ស័យ ថា មាន កូ វីត -១៩ ?

កោះសន្តិភាព KOH SANTEPHEAP MEDIA




# តើអាការៈឬសញ្ញាអ្វីខ្លះ ដែលសង្ស័យថាមានកូវីត-១៩ ?

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០
ម៉ោង ១៥:៥៤
គុច ណារ៉េន

Share

Like 238

ករណីបងប្អូនកំពុងមានការព្រួយបារម្ភ ពាក់ព័ន្ធនឹងការរីករាលដាលនៃវីរុសកូរ៉ូណា ឬCOVID-19 ជាពិសេស ពាក្យចចាមអារ៉ាមនានាពាក់ព័ន្ធនឹងការដួលសន្លប់ ឬដួលបាត់បង់ជីវិតនោះ ដូច្នេះ ការយល់ដឹងអំពីអាការៈរោគ ឬរោគសញ្ញាអ្វីខ្លះដែលសង្ស័យថា មានកូវីត-១៩ ឬអត់ជារឿងចាំបាច់?

លោកសាស្ត្រាចារ្យ វ៉ាន់ ម៉ិច ឯកទេសនិងប្រធានផ្នែកជំងឺសួតនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងជាប្រធានសមាគមគ្រូពេទ្យសួតកម្ពុជាបានឲ្យដឹងថា រោគសញ្ញាសង្ស័យនៃវីរុសកូរ៉ូណាគឺមានដូចជា ទី ១-មានកំដៅឡើងខ្ពស់ជាង៣៨ អង្សាសេ, អាការៈក្អកស្ងួត, ហត់ពិបាកដកដង្ហើមជាដើម។ ដូច្នេះ បើសិនបងប្អូនមានអាការៈរោគសញ្ញាខាងលើ បងប្អូនគួរទៅធ្វើតេស្តសុខភាព ។

ជាមួយគ្នានោះផងដែរ លោកសាស្ត្រាចារ្យ វ៉ាន់ ម៉ិច បានបញ្ជាក់ថាកន្លងមក មន្ទីរពេទ្យខ្មែរសូវៀត ក៏មានករណីអ្នកជំងឺសង្ស័យមាន covid-19 ចំនួន៧៨ករណី ដែលក្នុងនោះមានទាំងជនជាតិខ្មែរ និងបរទេសដូចជា ចិន ជប៉ុន កូរ៉េ និងអូស្ត្រាលីជាដើម ក្នុងនោះក៏មាននិសិត្សខ្មែរមកពីចិន៤២ នាក់គឺតេស្តអវិជ្ជមានដូចគ្នា ៕

## ៩. កោះសន្តិភាព៖ទប់ទល់ វីរុស COVID-19 អ៊ីតាលី ឈាន ដល់ បិទទ្វារសាលា






ទំព័រមុខ ▸ ព័ត៌មានអន្តរជាតិ ▸ ព្រឹត្តិការណ៍អន្តរជាតិ ▸ ទប់ទល់វីរុស COVID-19 អុ៊ីតាលីឈានដល់បិទទ្វារសាលា

# ទប់ទល់វីរុស COVID-19 អ៊ីតាលីឈានដល់បិទទ្វារសាលា

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០ ម៉ោង ១៧:១៥ ខាន់ សុខឃន

Share Like 451

អត្រាប្តូរប្រាក់

| ប្រាក់រៀល (1USD) | KHR 1USD : 4087 |
|---|---|

អត្រាប្តូរប្រាក់ផ្សេងទៀត >



ប្រទេសអ៉ីតាលី ៖ អ៉ីតាលី ប្រទេសដំបូងជាប្រភពនៃការចម្លងវីរុសCOVID-19 នៅអឺរ៉ុប ដែលចំនួនអ្នកបាត់បង់ជីវិតមកដល់ថ្ងៃទី៤មីនាឡើងដល់លើសពី១០០នាក់ គឺ១០៧នាក់ ក្នុងចំណោមអ្នកឆ្លងឡើងដល់៣.០៨៩នាក់ បានចាត់បណ្តាវិធានការវិសាមញ្ញនានា ដោយបណ្តាសាលារៀននិងសាកលវិទ្យាល័យត្រូវបិទទ្វារចាប់ពីថ្ងៃទី៥មីនាទៅរហូតដល់ថ្ងៃទី១៥មីនា។


SPONSORED NEWS




ទឹកចិត្តប្រពៃអ្នកនាង ស្រីអូន ចែកអំណោយថ្ងៃ៨មីនា រំជួលចិត្តហូរទឹកភ្នែក





នាយករដ្ឋមន្ត្រី អ៉ីតាលី លោកGIUSEPPE CONTE ពុំបដិសេធឡើយដែលថា បណ្តាមន្ទីរពេទ្យអាចមានអ្នកជំងឺហូរចូលលើសចំណុះ ក្នុងករណីមានកំណើនខ្ពស់នៃអ្នកជំងឺដែលធ្ងន់ធ្ងរ។ លោកបានព្រមានថា ពុំមែនប្រទេស អ៉ីតាលី តែមួយទ ទោះប្រទេសណាមួយនៃពិភពលោកក៏អាចប្រឈមមុខនឹងសភាពការណ៍បែបនេះដែរ។

ក្នុងរយៈពេលតែប៉ុន្មានសប្តាហ៍ ម៉ាស់ ថ្នាំសម្លាប់មេរោគ ស្រោមដៃឬសម្លៀកបំពាក់ការពារ ក្នុងប្រទេសជាច្រើនបានក្លាយទៅជាពិបាករក។ បន្ទាប់ពីបារាំងដែលប្រមូលស្តុកនិងជម្រុញផលិតកម្មម៉ាស ប្រទេសរុស្ស៊ីនាថ្ងៃទី៤មីនាបានហាមឃាត់ការនាំចេញបណ្តាសម្ភារការពារ អាល្លឺម៉ង់ក៏បានធ្វើតាមនេះដែរ។ រដ្ឋមន្ត្រីសុខាភិបាលអាល្លឺម៉ង់លោកJENS SPAHN ទើបហា៊ននិយាយជាលើកដំបូង ពាក្យថាវីរុសនោះឆ្លងរាលដាលដោយអះអាងថា ការឆ្លងវីរុសCOVID-19នៅចិន បានប្រែក្លាយទៅជាការឆ្លងរាលដាលលើពិភពលោកទាំងមូល ។ បច្ចុប្បន្នវីរុស COVID-19ប៉ះពាល់ដល់ប្រទេសនិងដែនដីដល់ទៅ៨១ហើយបានឆ្លងដល់មនុស្សជិត៩៥.០០០នាក់ រួចមនុស្សជាង៣.២០០នាក់បានត្រូវបាត់បង់ជីវិត។






វីរុសCOVID-19ពេលនេះប៉ះពាល់ដល់គ្រប់ទ្វីបទាំងអស់ លើកលែងតែតំបន់អង់តាក់ទិក និងធ្វើឲ្យស្ទះដល់ជីវភាពប្រចាំថ្ងៃរបស់ប្រទេសកាន់តែច្រើន។ ប្រឈមមុខនឹងគ្រោះថ្នាក់អាជ្ញាធរនៃប្រទេសទាំងឡាយ បានលុបចោលឬពន្យារពេលរៀបចំធ្វើរាល់ព្រឹត្តិការណ៍ឬការប្រមូលផ្តុំមនុស្សច្រើន ដែលអាចចម្លងជំងឺ។

នៅអង់គ្លេសសូម្បីបណ្តាផលិតករខ្សែភាពយន្តជេមប៊នថ្មី រឿងNO TIME TO DIEក៏ប្រកាសពន្យារពេលចេញបញ្ចាំងលើពិភពលោកនាខែវិច្ឆិកាដែរ។ ការប្រមូលផ្តុំមនុស្សបែបសាសនា ក៏ហាមឃាត់។ អារ៉ាប៊ីសាអូឌីតបានសម្រេចផ្អាកបណ្តោះអាសន្នធម្មយាត្រាអ៊ិស្លាមប្រចាំឆ្នាំ៕ ដកស្រង់ចេញពីវេបសាយ ៖ yahoo (កែសម្រួលដោយ ៖ បុប្ផា)

## ១០. កោះសន្តិភាព៖ជំងឺ កូ រ៉ូ ណា អាច ប៉ះពាល់ កំណើន សេដ្ឋកិច្ចជាតិ ថយ ពី ប្រមាណ ៧% មក ត្រឹម ៦.១% ក្នុង ឆ្នាំ ២០២០

កោះសន្តិភាព KOH SANTEPHEAP MEDIA

រាជធានីភ្នំពេញ ៖ លោក មាស សេនសាន អ្នកនាំពាក្យ និងជាអគ្គលេខាធិការដ្ឋាននៃអគ្គនាយកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្លែងថា ក្នុងឆ្នាំ២០២០នេះ មានការប៉ះពាល់មួយចំនួនដោយមានការថមថយពីកំណើនជាង ៧% មកត្រឹម៦.១% ។

លោក មាស សេនសានបន្តថា ក្រសួងសេដ្ឋកិច្ចបានគិតគូររួចហើយពីផលប៉ះពាល់ដូចជា កត្តាពាណិជ្ជកម្មនិងកត្តាផ្សេងៗដែលបណ្តាលមកពីជំងឺកូវីដ១៩ ជាសកលនេះ ។ ក្រសួងកំពុងឃ្លាំមើលពីរយៈពេលអូសបន្លាយពីការគំរាមកំហែងពីការផ្ទុះនៃមេរោគនេះ និងវិស័យណាដែលប៉ះពាល់ជាងគេ ។

លោក មាស សេនសាន ថ្លែងដូចខាងលើក្នុងសន្និសីទសារព័ត៌មាននៅព្រឹកថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០នេះ នៅអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលចំពោះករណីវីរុសកូរ៉ូណា ឬកូវីដ១៩នេះ ក្រសួងសេដ្ឋកិច្ចបន្តអនុវត្តម៉ាក្រូសេដ្ឋកិច្ច ដោយប្រុងប្រយ័ត្នតាមរយៈយុទ្ធសាស្រ្តមីក្រូហិរញ្ញវត្ថុដល់ឆ្នាំ២០២៥ ។ បន្តពង្រឹងការគ្រប់គ្រងចំណូល និងចំណាយឆ្នាំ២០១៩ និងឆ្នាំ២០២៥ ព្រមទាំងប្រឆាំងអំពើពុករលួយ ។

ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចប្រមាណ៧% ដែលកម្ពុជាសម្រេចបានចំណូលមធ្យមកម្រិតទាប ។ លោកមាស សេនសាន លើកឡើងទៀតថា ក្នុង ២០១៩ ចំណូលរបស់មនុស្សម្នាក់ៗមានប្រមាណ១៦៧៩ដុល្លារអាមេរិកក្នុង១ឆ្នាំ ។ ក្នុងនោះអត្រាភាពក្រីក្របានកាត់បន្ថយមកនៅត្រឹមក្រោម១០ភាគរយ ។

លោក មាស សេនសានបន្តថា បើគិតពីការកៀងគរចំណូលថវិកាជាតិ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋគិតពីឆ្នាំ២០១៣ ដល់ឆ្នាំ ២០១៨ ចំណូលថវិការដ្ឋកើនឡើងពីរដងចំនួន២ពាន់២រយហុកសិបលានដុល្លាអាមេរិកដល់ប្រមាណ៤ពាន់៥រយ៦៤លានដុល្លារអាមេរិក ។ មន្ត្រីក្រសួងសេដ្ឋកិច្ចបានបញ្ជាក់ថា ដោយបញ្ហាកូវីដ១៩នេះរដ្ឋាភិបាលបានដាក់ចេញនូវគោលការណ៍មិនយកពន្ធ

## ១១. កោះសន្តិភាព៖COVID19: សំពះ ប្រើ កែងដៃ និង កែងជើង ជំនួស ការ ចាប់ដៃ ការ អោប និង ថើប ដើម្បី ស្វាគមន៍ គ្នា




# COVID19: សំពះប្រើកែងដៃ និង កែងជើងជំនួសការចាប់ដៃ ការអោប និង ថើប ដើម្បីស្វាគមន៍គ្នា

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០
ម៉ោង ១៣:១៧
វ័ត្ថ ធីយ៉ា

Share

Like 203

មេរោគ កូវីដ១៩ មិនត្រឹមតែធ្វើមានមនុស្សស្លាប់ ឈឺ និងប៉ះពាល់ដល់សេដ្ឋកិច្ច និង ការធ្វើដំណើររបស់មនុស្សទេ ។ វាថែមទាំងធ្វើអោយមានការផ្លាស់ប្តូរផងដែរ ពីរបៀបដែលមនុស្សស្វាគមន៍គ្នានៅពេលជួបគ្នា ។

យោងតាមសេចក្តីរាយការណ៍ព័ត៌មានបរទេសនោះការថើប និងការអោបគ្នា ដើម្បីស្វាគមន៍គ្នាត្រូវបានណែនាំអោយចៀសវាង ។ ប្រជាជននៅប្រទេសខ្លះបានផុលកែងដៃគ្នាជំនួសវិញ ដើម្បីធ្វើជាការស្វាគមន៍គ្នា ។ ចំណែកប្រជាជនខ្លះទៀត នៅក្នុងពិភពលោកគេបានប្រើជើងប៉ះគ្នា ដើម្បីជាមធ្យោបាយថ្មីនៃការស្វាគមន៍គ្នា ។

ចំណែកនៅប្រទេសកម្ពុជាវិញ សម្តេចតេជោហ៊ុន សែន បានណែនាំអោយធ្វើការសំពះ ស្វាគមន៍គ្នាជំនួស អោយការចាប់ដៃគ្នា។ មកដល់ពេលនេះ មេរោគដ៏សាហាវមួយនេះបានរាលដាលចូលដល់ប្រទេសជាង៧០ ហើយនៅក្នុងពិភពលោក ហើយវាបានធ្វើអោយមនុស្សជាង៩០០០០នាក់ធ្លាក់ខ្លួនឈឺ ។

# ១២. កោះសន្តិភាព៖ប្រជាជន កម្ពុជា ត្រូវ យល់ ដឹង អំពី វិធី កុំអោយ ឆ្លង មេរោគ កូ វី ដ ១៩




## ប្រជាជនកម្ពុជាត្រូវយល់ដឹងអំពីវិធីកុំអោយឆ្លងមេរោគកូវីដ១៩

ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២០
ម៉ោង ១២:៥៩
ប្រេវីន

Share

Like 7K

វាជារឿងដ៏ល្អមួយដែលរហូតមកទល់ពេលនេះមិនទាន់មានប្រជាជនកម្ពុជាណាម្នាក់ត្រូវបានរកឃើញថា បានឆ្លងមេរោគកូវីដ១៩នេះនៅឡើយទេ ។ ប៉ុន្តែនេះមិនមានន័យថាយើងត្រូវព្រងើយកន្តើយនឹងមេរោគនេះឡើយ ។

តាមទ្រឹស្តីវេជ្ជសាស្ត្រ ការចាត់វិធានការបង្ការបានមុនវាជារឿងដ៏ល្អមួយ ដើម្បីទប់ទល់នឹងជំងឺគ្រប់ប្រភេទ ហើយវារឹងតែសំខាន់ទៀតនៅពេលនេះ ដើម្បីទប់ស្កាត់កូវីដ១៩ ។

ខណៈដែលយើងត្រូវតែរក្សាភាពស្ងប់ស្ងាត់ ហើយចៀសវាងការភ័យខ្លាចដែលមិនសមហេតុផលនោះវាចាំបាច់ណាស់ដែលមនុស្សគ្រប់គ្នាមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីធ្វើយ៉ាងណាអោយខ្លួនអាចចៀសផុតពីការឆ្លងមេរោគដ៏កាចសាហាវមួយនេះ ។

ប្រជាជនកម្ពុជាអាចបង្កើនចំណេះដឹងទាក់ទងនឹងមេរោគកូវីដ១៩ នេះ តាមរយៈការតាមដានអោយជាប់លាប់បំផុតរាល់ការផ្សាយព័ត៌មានទាក់ទងនឹងមេរោគនេះ ពិសេសវិធានការបង្ការដែលត្រូវប្រកាន់យក ដើម្បីធ្វើយ៉ាងណាអោយចៀសផុតពីមេរោគនេះ ។

ក្រសួងសុខាភិបាលត្រូវពង្រីកការផ្សព្វផ្សាយអំពីរោគសញ្ញាអំពីវិធីចម្លងវិធីការពារ និង របៀបស្វែងរកជំនួយ អោយមានការទូលំទូលាយបំផុត ទៅដល់គ្រប់ទីកន្លែងទូទាំងប្រទេស ។ ការផ្សព្វផ្សាយនេះអាចនឹងជួយអោយប្រជាជនមានចំណេះ ដឹងគ្រប់គ្រាន់ដើម្បីដឹងពីវិធីបង្ការការឆ្លងមេរោគ ការចៀសវាងការចម្លងមេរោគ និងការដឹងរោគសញ្ញានៃជំងឺដើម្បីឆាប់រាយការណ៍ និង វិធីលើកកម្ពស់សុខភាពផ្ទាល់ខ្លួនដើម្បីមានភាពរឹងមាំទល់នឹងជំងឺនានា ។ សារសំខាន់ដូចគ្នានេះ ព័ត៌មានដែលផ្សព្វផ្សាយដោយក្រសួងសុខាភិបាលក៏ជួយទប់ស្កាត់ផងដែរ ការភ័យជ្រួលច្របល់ដែលអាចជះឥទ្ធិពលដោយសារការផ្សព្វផ្សាយព័ត៌មានមិនពិតតាមបណ្តាញសង្គម ។

អ្នកវិទ្យាសាស្រ្តកំពុងតែសិក្សាស្រាវជ្រាវនៅឡើយដើម្បីអោយយល់កាន់តែច្បាស់អំពីវិធីដែលមេរោគនេះចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់។ ការចម្លងមេរោគអាចកើតមានបាន នៅពេលមនុស្សនៅជិតគ្នាពេក ជាមួយនឹងមនុស្សដែលមានមេរោគ ឬក៏នៅពេលដែលអ្នកមានមេរោគក្អកឬកណ្តាសបញ្ចេញ មេរោគ នេះដែលអាចធ្វើអោយវាខ្ទាតចូលដល់ផ្លូវដង្ហើមរបស់មនុស្សដែលនៅក្បែរនោះ។

ដូច្នេះ ជាបឋមប្រជាជនកម្ពុជាត្រូវយល់ដឹងថា មេរោគនេះអាចចម្លងតាមរយៈការក្អក ការកណ្តាស ការចាប់ដៃ ការអោបថើប

ជាមួយ និងការនៅជិតអ្នកដែលមានមេរោគ។ យោងតាមមជ្ឈមណ្ឌល គ្រប់គ្រងជំងឺអាមេរិកនោះ មេរោគនេះក៏អាចចម្លងមកមនុស្សផងដែរតាមរយៈការប៉ះឬកាន់ កន្លែងណាមួយដែលមានមេរោគស្ថិតនៅ។

ចំណែកឯវិធានការដែលប្រជាជនកម្ពុជាអាចប្រកាន់យកដើម្បីចៀសវាងការឆ្លងមេរោគនេះនោះអាចរួមមានការចៀសវាងធ្វើដំណើរទៅកាន់កន្លែងដែលមានការរាលដាលមេរោគនិងការអនុវត្តអនាម័យអោយបានល្អ ។ ដូច្នេះវិធីការពារខ្លួនអ្នក និងអ្នកដទៃអាចមានដូចខាងក្រោមនេះ។

- លាងដៃរបស់អ្នក ៖ ចូរលាងសម្អាតដៃរបស់អ្នកជាមួយសាប៊ូ និងទឹកហូរស្អាត ( ទឹករ៉ូប៊ីណេ)។ លាងសម្អាតដៃរួមទាំងខ្នងដៃ ចន្លោះម្រាមដៃ និងនៅក្រោមក្រចករបស់អ្នក ក្នុងរយៈពេលយ៉ាងហោច ណាស់ ២០ វិនាទី មុនពេលលាងទឹកជម្រះ។
- គ្របមាត់ និងច្រមុះរបស់អ្នកដោយក្រដាសស្អាត មុនពេលអ្នកក្អក ឬកណ្តាស់ បន្ទាប់មកបោះ វាចោលក្នុងធុងសំរាម ហើយលាងដៃរបស់អ្នក។ ប្រសិនបើអ្នកមិនមានក្រដាសជូតមាត់នៅជិតខ្លួន ចូរក្អក ឬកណ្តាស់ក្នុងកែងដៃរបស់អ្នកជាជាងក្នុងដៃរបស់អ្នក។
- ម៉ាស់ ឬរបាំងមុខផ្តល់នូវការការពារមួយចំនួន។ ម៉ាស់អាចផ្តល់នូវការការពារខ្លះ ខណៈពេលដែល ពួកវារារាំងដំណក់ទឹក។ ទោះយ៉ាងណាក៏ដោយ ពួកវាមិនអាចរារាំងភាគល្អិតតូចៗដែលអាចឆ្លង កាត់ ម៉ាស់នោះទេ។ ម៉ាស់មិនអាចបិទភ្នែកអ្នកជិតនោះទេ ហើយដែលថាវីរុសខ្លះអាចចម្លងពីមនុស្ស ម្នាក់តាមរយៈភ្នែក។
- ស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ ។ ចូរទៅជួបគ្រូពេទ្យ នៅពេលពេលអ្នកក្តៅខ្លួន ក្អក និងពិបាកដកដង្ហើម ហើយចូរប្រាប់ប្រវត្តិធ្វើដំណើររបស់អ្នកទៅកាន់គ្រូពេទ្យរបស់អ្នក។
- ប្រសិនបើអ្នកទើបតែវិលត្រឡប់មកពីតំបន់ដែលរងមានឆ្លងវីរុសនេះ ក្នុងរយៈពេលពីរសប្តាហ៍ចុង ក្រោយនេះ ចូរស្នាក់នៅក្នុងផ្ទះ និងជៀសវាងការទាក់ទងជាមួយមនុស្សផ្សេងទៀតក្នុងរយៈពេល ១៤ ថ្ងៃ។ នេះគឺមានន័យថា មិនទៅធ្វើការ មិន

ទៅសាលារៀន ឬកន្លែងសាធារណៈ។

នៅពេលដែលប្រជាជនកម្ពុជាម្នាក់ៗមានការយល់ដឹងកាន់តែខ្ពស់អំពីរបៀបចម្លងមេរោគ រោគសញ្ញាដែល បណ្តាលមកពីជំងឺដោយមេរោគកូវីដ១៩ វិធីបង្ការការចម្លងមេរោគ និង ចំណេះដឹងផ្សេងៗទៀតទាក់ ទងនឹងមេរោគនេះនោះ ពួកគេនឹងអាចបង្ការខ្លួនពីជំងឺនេះហើយកាត់បន្ថយផល ប៉ះពាល់នៃជំងឺនេះ មកលើសេដក្ឋកិច្ចនិងសង្គមកម្ពុជា។

អ្វីដែលធ្វើអោយពិភពលោកទាំងមូលបារម្ភនោះគឺមេរោគនេះបានរាលដាលដល់ជាង៧០ប្រទេសក្នុងពិភពលោកហើយមនុស្សជាង៩ម៉ឺននាក់បានឆ្លងមេរោគនេះ ហើយជាង ៣០០០នាក់បានស្លាប់ដោយ សារមេរោគនេះ ៕

## ១៣. កម្ពុជាថ្មី៖ឆ្លើយ តប នឹង ស្ថានភាព បច្ចុប្បន្ន នៃជំងឺ កូវីត-១៩ ក្រសួង អប់រំ យុវជន និង កីឡា អនុវត្តវិធាន ការ ៧ចំណុច

# ឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន នៃជំងឺ កូវីត-១៩ ក្រសួងអប់រំ យុវជន និង កីឡា អនុវត្តវិធានការ៧ចំណុច

5/3/2020 7:44 Pm ជាតិទូទៅ, ព័ត៌មានជាតិ like

ភ្នំពេញ ៖ ឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន នៃជំងឺរាតត្បាត រលាកសួត កូវីត-១៩ (COVID-19) ក្រសួងអប់រំ យុវជន និងកីឡា ធ្វើការណែនាំអង្គភាពពាក់ព័ន្ធ និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ត្រូវណែនាំបុគ្គលិក និងអ្នកសិក្សា អនុវត្តវិធានការ៧ចំណុច។

ដោយយោងតាមលិខិតរបស់ ក្រសួងអប់រំ យុវជន និងកីឡា ដែលកម្ពុជាថ្មីទទួលបាន នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០នេះថា ដោយស្ថានភាពបច្ចុប្បន្ន ការរាតត្បាតនៃជំងឺរលាកសួតកូវីដ១៩ (COVID-19) នៅជុំវិញពិភពលោកមិនទាន់មានថ្នាំព្យាបាល ឬ វ៉ាក់សាំងបង្ការនៅឡើយ ព្រមទាំងផ្ទុះឡើងវិញនៃជំងឺផ្តាសាយនានា ដូចជា ផ្តាសាយបក្សី "H5N1" និងផ្តាសាយជ្រូក "H1N1" នៅតាមបណ្តាប្រទេសមួយចំនួននៅទ្វីបអាស៊ីនោះ ក្រសួងអប់រំ យុវជន និងកីឡា បានចាត់វិធានការ ៧ចំណុច មានដូចជា ៖

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ១០ អយក.សលាន

## សេចក្ដីណែនាំបន្ថែម
## ស្ដីពី
## ការអនុវត្តវិធានការបង្ការជំងឺរលាកសួតដោយកូវីដ-១៩ (Covid-19) និងជំងឺរលាកផ្លូវដង្ហើមដទៃទៀត នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

ឆ្លើយតបទៅនឹងស្ថានភាពនៃការរាតត្បាតជំងឺរលាកសួត-កូវីដ-១៩" (Covid-19) នៅជុំវិញពិភពលោក ដោយមិនទាន់មានថ្នាំព្យាបាល ឬវ៉ាក់សាំងបង្ការនៅឡើយ ព្រមទាំងការផ្ទុះឡើងវិញនៃជំងឺផ្ដាសាយនានា ដូចជា ផ្ដាសាយបក្សី"H5N1" និងផ្ដាសាយជ្រូក"H1N1" នៅតាមបណ្ដាប្រទេសមួយចំនួននៅទ្វីបអាស៊ី និងក្នុងគោលបំណងជំរុញការអនុវត្តវិធានការបង្ការទប់ស្កាត់ជំងឺទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំបន្ថែមដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត អង្គភាពពាក់ព័ន្ធ និងគ្រឹះស្ថានសិក្សា សាធារណៈ និងឯកជនទាំងអស់ ត្រូវណែនាំបន្តដល់បុគ្គលិកអប់រំ និងអ្នកសិក្សា ឱ្យអនុវត្តនូវវិធានការដូចខាងក្រោម៖

១. ត្រូវចាត់តាំងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា១រូប ឱ្យទទួលបន្ទុកសណ្ដាប់ធ្នាប់និងការងារលើកកម្ពស់សុខភាពសិក្សា ដើម្បីអនុវត្តវិធានការឆ្លើយតបក្នុងការបង្ការទប់ស្កាត់ ជំងឺរាតត្បាតខាងលើ។

២. ត្រូវពង្រឹងសណ្ដាប់ធ្នាប់ចេញចូលនៅតាមគ្រឹះស្ថានសិក្សា ដោយពង្រឹងវិន័យ និងមិនឱ្យជនគ្មានភារកិច្ចចេញចូលដោយគ្មានការអនុញ្ញាត។

៣. ត្រូវរៀបចំទឹកស្អាតសម្រាប់ទទួលទានឱ្យបានយ៉ាងហោច៥០០មីលីលីត្រសម្រាប់អ្នកសិក្សានិងបុគ្គលិកអប់រំម្នាក់ៗ ក្នុង១វេនសិក្សា និងលើកទឹកចិត្តឱ្យយកទឹកស្អាតសម្រាប់ទទួលទានពីផ្ទះរៀងៗខ្លួន។

៤. ត្រូវរៀបចំឱ្យមានទឹកស្អាតនិងសាប៊ូលាងដៃជាប្រចាំនៅជិតបន្ទប់រៀន បន្ទប់ទឹក និងបង្គន់អនាម័យ។

៥. ត្រូវពិនិត្យលទ្ធភាពរៀបចំឧបករណ៍វាស់កម្ដៅអ្នកសិក្សានិងបុគ្គលិកអប់រំ នៅច្រកទ្វារចូល ឬទីតាំងការរៀងរាល់ថ្ងៃ ករណីមានកម្ដៅលើសពី៣៨អង្សាសេ ត្រូវអនុញ្ញាតឱ្យឈប់សម្រាក ឬណែនាំឱ្យទៅទទួលសេវានៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិត។

៦. ត្រូវតាមដាន និងពិនិត្យសុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំ ដោយសាកសួររកពេគសញ្ញាសង្ស័យរបស់អ្នកសិក្សានិងបុគ្គលិកដូចជាក្ដៅ កណ្ដាស់ ផ្ដាសាយ ហៀរសំបោរ ឈឺក្បាល ឈឺបំពង់កពិបាកដកដង្ហើម ក្អក ឬក្អួត និងណែនាំឱ្យទៅទទួលសេវាព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិត។

៧. ត្រូវអប់រំផ្សព្វផ្សាយដល់អ្នកសិក្សានិងបុគ្គលិកអប់រំ ឱ្យបង្កើនការយល់ដឹងអំពីការថែរក្សាសុខភាព និងយកចិត្តទុកដាក់វិធានការបង្ការ ដូចខាងក្រោម៖

- គេងឱ្យបានគ្រប់គ្រាន់ (៨ម៉ោងក្នុង១ថ្ងៃ)



- ទទួលទានទឹកឱ្យបានញឹកញាប់ យ៉ាងតិច២លីត្រក្នុង១ថ្ងៃ
- ទទួលទានអាហារយ៉ាងតិចបីពេលឱ្យបានគ្រប់គ្រាន់ក្នុង១ថ្ងៃ
- ធ្វើលំហាត់ប្រាណ៣០នាទី ឱ្យបានទៀងទាត់ យ៉ាងតិច ៣ទៅ៥ថ្ងៃ ក្នុង១សប្ដាហ៍
- អនុវត្តវិធានការអនាម័យជាប់ជាប្រចាំ ត្រូវលាងសម្អាតដៃជាមួយទឹកស្អាត និងសាប៊ូឱ្យបានញឹកញាប់ ពិសេសមុនចាប់កាន់ចំណីអាហារទទួលទាន ឬក្រោយចេញពីបង្គន់អនាម័យ
- ចៀសវាងការយកដៃប៉ះភ្នែក មាត់ ច្រមុះ
- ចៀសវាងការពិសាបារីនិងគ្រឿងស្រវឹងគ្រប់ប្រភេទ
- បើមិនចាំបាច់ កុំទៅទីប្រជុំជនដែលមានមនុស្សច្រើន ករណីចាំបាច់ត្រូវពាក់ម៉ាស ឬក្រមាគ្របលើមាត់និងច្រមុះ សម្រាប់បង្ការពីការឆ្លងជំងឺ
- លើកកម្ពស់ការគោរពគ្នាទៅវិញទៅមកដោយកាយវិការសំពះតាមទំនៀមទម្លាប់ខ្មែរ
- បរិភោគអាហារដែលឆ្អិនល្អពិសេសសាច់និងស៊ុតគ្រប់ប្រភេទ
- កុំលេងសត្វបក្សី សត្វចិញ្ចឹមគ្រប់ប្រភេទ ក្នុងករណីប៉ះផ្ទាល់ជាមួយសត្វទាំងនោះត្រូវលាងសម្អាតដៃជាមួយទឹកស្អាតនិងសាប៊ូភ្លាម
- គ្រប់គ្រងអារម្មណ៍ខ្លួនឯងឱ្យបានល្អ
- ប្រើប្រាស់និងជឿជាក់លើប្រព័ន្ធព័ត៌មានដែលមានប្រភពច្បាស់លាស់។

ទទួលបានសេចក្ដីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ខណ្ឌ ស្រុក និងគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ដើម្បីអនុវត្តឱ្យបានលទ្ធផលល្អប្រសើរនិងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- សាលារាជធានី-ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទទីស្ដីការក្រសួង
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត "ដើម្បីមុខការ"
- កាលប្បវត្តិ
- ឯកសារ នា.សុខភាពសិក្សា

## ១៤. កម្ពុជាថ្មី៖ប្រទេសអ៊ីរ៉ង់ផលិតម៉ាស៊ីនថតកម្តៅដើម្បីស្វែងរកវីរុសកូរ៉ូណានៅទីសាធារណៈ

# ប្រទេសអ៊ីរ៉ង់ផលិតម៉ាស៊ីនថតកម្ដៅដើម្បីស្វែងរកវីរុសកូរ៉ូណានៅទីសាធារណៈ

5/3/2020 3:56 Pm KPT Plus, បច្ចេកវិទ្យា, ព័ត៌មានអន្តរជាតិ, សុខភាព like

ប្រទេសអ៊ីរ៉ង់បានអភិវឌ្ឍចំណេះដឹងបច្ចេកទេសក្នុងការផលិតប្រព័ន្ធម៉ាស៊ីនថតកម្ដៅថ្មីសម្រាប់ពិនិត្យអាការៈគ្រុនក្ដៅតាមទីសាធារណៈនានានៅក្នុងស្រុក។

នៅក្នុងបទសម្ភាសន៍ជាមួយសារព័ត៌មាន ISNA នាយកមជ្ឈមណ្ឌលយុទ្ធសាស្ត្របច្ចេកវិទ្យា និងជាអនុប្រធានាធិបតីអ៊ីរ៉ង់នៃនាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាលោក Esmaeil Qaderifar បាននិយាយកាលពីថ្ងៃទី៤ ខែមីនា ម្សិលមិញថា ផែនការអភិវឌ្ឍម៉ាស៊ីនថតកម្ដៅត្រូវបានដាក់ចេញបន្ទាប់ពីការផ្ទុះឡើងនៃវីរុសកូរ៉ូណានៅក្នុងប្រទេសអ៊ីរ៉ង់ គឺដើម្បីបំពេញតម្រូវការរបស់ប្រទេសក្នុងប្រព័ន្ធបច្ចេកវិទ្យាទំនើប។

យោងតាមសម្ដីរបស់លោក Qaderifar អនុប្រធានគណៈកម្មការវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលជាអ្នកឧបត្ថម្ភគាំទ្រដល់សកម្មភាពផែនការណ៍បង្កើតម៉ាស៊ីនថតកម្ដៅបានឲ្យដឹងថា អ្នកស្រាវជ្រាវនៃក្រុមហ៊ុនក្នុងស្រុកបានបង្កើតម៉ាស៊ីនថតកម្ដៅដែលអាចរកឃើញគ្រុនក្ដៅដោយមានល្បឿនគ្នាពីឧបករណ៍ស្ទង់កម្ដៅប្រហែលកន្លះដីក្រែ។ មន្ត្រីអ៊ីរ៉ង់រូបនេះ ពន្យល់ថា ម៉ាស៊ីនថតត្រូវបានប្រើសម្រាប់ត្រួតពិនិត្យគ្រុនក្ដៅនៅតាមទីសាធារណៈដែលមានមនុស្សច្រើនដូចជាអាកាសយានដ្ឋាន ស្ថានីយនានា និងស្ថានីយរថភ្លើងក្រោមដីជា
លោក Qaderifar បានបន្ថែមថា វិធានការណ៍បែបនេះនឹងជួយអ៊ីរ៉ង់ឲ្យដើរទាន់ជាមួយប្រទេសដទៃទៀតក្នុងការឆ្លើយតបខាងបច្ចេកវិទ្យា និងការច្នៃប្រឌិតថ្មីចំពោះវីរុសកូរ៉ូណា។

គួរជម្រាបដែរថា ចំនួនអ្នកស្លាប់ដោយសារការឆ្លងរាលដាលនៃមេរោគកូរ៉ូណាក្នុងប្រទេសអ៊ីរ៉ង់បានកើនឡើងដល់ ៩២ នាក់នៅថ្ងៃព្រហស្បតិ៍នេះ ចំណែកចំនួនករណីឆ្លងសរុបបានកើនឡើងដល់ ២ ៩២២ នាក់ ក្នុងនោះមានមនុស្សចំនួន ៨៣៥ នាក់ក៏បានជាសះស្បើយពីជំងឺនៅក្នុងប្រទេសនេះដែរ៕

## ១៥. កម្ពុជាថ្មី៖ការសិក្សា៖ វីរុស COVID-19 អាច សិំចំលាក់ខ្លួនក្នុងបន្ទប់គេង និងបង្គន់ ប៉ុន្តែអាចងាប់ វិញ បើបាញ់ថ្នាំកម្ចាត់មេរោគ

# ការសិក្សា៖ វីរុស covid-19 អាចសំងំលាក់ខ្លួនក្នុងបន្ទប់គេង និងបង្គន់ ប៉ុន្តែអាចងាប់វិញបើបាញ់ថ្នាំកម្ចាត់មេរោគ

5/3/2020 3:37 Pm ព័ត៌មានអន្តរជាតិ, សុខភាព 2

ការសិក្សាស្រាវជ្រាវថ្មីមួយពីប្រទេសសិង្ហបុរីចុះផ្សាយកាលពីថ្ងៃពុធ បានបង្ហាញឲ្យឃើញថាអ្នកជំងឺដែលផ្ទុកវីរុស COVID-19 មានការឆ្លងយ៉ាងទំលំទូលាយនៅក្នុងបន្ទប់ដេក បន្ទប់ទឹក និងបង្គន់ ដែលជាទម្លាប់ជាចាំបាច់ត្រូវតែធ្វើការសម្អាតអនាម័យឲ្យបានជាប្រចាំ ជាពិសេសឧបករណ៍ប្រើប្រាស់នៅក្នុងបន្ទប់ទឹក និងបង្គន់ មានចានបត់ជើងជាដើម។

ទោះជាយ៉ាងណាក្តីវីរុសអាចត្រូវបានសម្លាប់ដោយសារតែការលាងសម្អាតធ្វើអនាម័យឲ្យបានពីរដងក្នុងមួយថ្ងៃ ជាំពិសេសគឺការជូតសម្អាតកម្រាលឥដ្ឋនៅក្នុងបន្ទប់ដំណេកឲ្យបានជាប្រចាំថ្ងៃ ដោយប្រើថ្នាំសម្លាប់សត្វល្អិត ដែលនេះជាវិធានការសម្រាប់ទប់ស្កាត់ការចម្លងរាលដាល ខណៈដែលមនុស្សស្ថិតនៅជាមួយនឹងវីរុស។

លិខិតមួយដែលបានមកពីការសិក្សាស្រាវជ្រាវចុះផ្សាយនៅក្នុងព្រឹត្តិបត្រព័ត៌មាន The Jounal of the Amercian Medical Association (JAMA) ហើយកើតមានបន្ទាប់ពីករណីជាច្រើននៃការឆ្លងវីរុសនៅក្នុងប្រទេសចិន ដែលរាលដាលដ៏ខ្លាំងក្លានៅតាមមន្ទីរពេទ្យរហូតដល់ចម្លងដល់បុគ្គលិកថែទាំ និងព្យាបាលអ្នកជំងឺដល់ទៅរាប់សិបនាក់រួមជាមួយនឹងអ្នកជំងឺផងដែលនោះ។ នេះនាំឲ្យអ្នកវិទ្យាសាស្ត្រជឿថាការឆ្លងតាមរយៈការក្អក ការឆ្លងតាមរយៈបរិស្ថាន ដែលកន្លងមក ចាត់ទុកជាកត្តាដ៏សំខាន់មួយនៃការឆ្លងវីរុសនោះ វានៅពុំទាន់មាន

ច្បាស់លាស់នៅឡើយទៅវិញទេ។

អ្នកសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិនៃជំងឺឆ្លងរបស់ប្រទេសសិង្ហបុរី និងបណ្តាមន្ទីរពិសោធន៍ជាតិ DSO បានផ្តោតទៅលើករណីនៃអ្នកជំងឺ៣នាក់ដែលត្រូវបានដាក់ឲ្យនៅដោយឡែកពីគាតាមបន្ទប់ពិសេសៗរវាងចុងខែមករានិងដើមខែកុម្ភៈ។ តាមរយៈការតាមដានស្រាវជ្រាវគេបានប្រមូលយកសំណាកទាំងឡាយពីក្នុងបន្ទប់នៃមន្ទីរពេទ្យដែលគេកំពុងស្នាក់ព្យាបាលចាប់ពី៥ថ្ងៃដល់២សប្តាហ៍ម្ល៉ោះហើយតាមសំណាកនៃអ្នកជំងឺទាំង២នាក់នោះទើបបានគេដាក់ចេញនូវវិធានការបាញ់សម្លាប់វីរុសដោយថ្នាំកម្ចាត់មេរោគតែម្តង៕ អាអេហ្វ ប៉េ

ប្រែសម្រួល៖ ស.ប.ឆ

## ១៦. កម្ពុជាថ្មី៖សុខាភិបាលកម្ពុជា បដិសេធដំណឹងពីសារព័ត៌មាន សិង្ហបុរីដែលថា កម្ពុជា មានករណីឆ្លង១៦នាក់

# សុខាភិបាលកម្ពុជាបដិសេធដំណឹងពីសារព័ត៌មានសិង្ហបុរីដែលថា កម្ពុជាមានករណីឆ្លង១៦នាក់

5/3/2020 11:51 Am ព័ត៌មានជាតិ, ព័ត៌មានថ្មីៗ, សុខភាព 1

ភ្នំពេញ៖លោកស្រីវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងសុខាភិបាលបានធ្វើការបដិសេធន៍ថា តារាងតួលេខដែលខាងសារព័ត៌មានរបស់សិង្ហបុរី (CNA) បានធ្វើការផ្សព្វផ្សាយដែលថា កម្ពុជាមានឆ្លងជំងឺកូវីដ១៩ចំនួន៦នាក់នោះគឺជាព័ត៌មានមិនពិតនោះទេ។

លោកស្រីវេជ្ជបណ្ឌិតបានបញ្ជាក់ថា រហូតមកដល់ពេលនេះកម្ពុជានៅមិនទាន់មានករណីឆ្លងថ្មីជំងឺកូវីដ១៩នៅឡើយទេ ពោលគឺមានតែមួយករណីទៅលើជនជាតិចិនអាយុ៦០ឆ្នាំនៅខេត្តព្រះសីហនុបានជាសះស្បើយ និងបានវិត្រឡប់ទៅប្រទេសខ្លួនវិញ។ ចំពោះករណីជនជាតិជប៉ុនដែលបានចេញពីសៀមរាបទៅវៀតណាមហើយត្រូវបានរកឃើញថាមានឆ្លងជំងឺកូវីដ១៩នោះក្រសួងកំពុងតាមដាននិងធ្វើការស្រាវជ្រាវបន្តហើយនឹងបង្ហាញនៅសន្និសីតកាសែតនៅរសៀលនេះ។

យោងតាមផេកហ្វេប៊ុករបស់លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានលើកឡើងដោយស្រង់សំដីលោកអភិបាលខេត្តសៀមរាបបញ្ជាក់ថា ថ្មីៗនេះ ការផ្សព្វផ្សាយជុំវិញព័ត៌មានថា ចំពោះជនជាតិជប៉ុនម្នាក់បានឆ្លងជំងឺ COVID-19 ដែលបានហោះចេញពីព្រលានយន្តហោះអន្តរជាតិសៀមរាបឆ្លងកាត់ព្រលានយន្តហោះ ទីក្រុងហូជីមិញប្រទេសវៀតណាម រួចបន្តដំណើរទៅប្រទេសជប៉ុន។

លោក ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្ត បានគូសបញ្ជាក់ថាជនជាតិជប៉ុនរូបនេះគឺគាត់ជាអ្នករស់នៅនិងប្រកបអាជីវកម្មនៅក្នុងខេត្តសៀមរាបមិនមែនមកដំណើរកំសាន្តលក្ខណៈទេសចរណ៍នោះទេ។ អាជ្ញាធរខេត្តបានយកចិត្តទុកដាក់ខ្ពស់លើបញ្ហានេះដោយបានសហការជាមួយនឹងកុងស៊ុលជប៉ុនប្រចាំខេត្តសៀមរាប មន្ទីរនិងក្រសួងសុខាភិបាលសុខាភិបាល។

តាមការបញ្ជាក់របស់មន្ត្រីសុខាភិបាលខេត្ត និងភាគីកុងស៊ុលជប៉ុនប្រចាំខេត្ត បានបញ្ជាក់ថាមុនចេញដំណើរការពិនិត្យសុខភាពជនជាតិជប៉ុនរូបនេះពុំមានរោគសញ្ញាកើតជំងឺ COVID-19នោះឡើយ។

ម្យ៉ាងវិញទៀត ភាគីជប៉ុនបានបញ្ជាក់ថាក្រសួងសុខាភិបាលជប៉ុន ពុំទាន់បានជូនដំណឹងជាផ្លូវការ ថាជនជាតិជប៉ុនរូបនេះមានឆ្លងនឹងកើតជំងឺ COVID-19 នៅឡើយ។ ទន្ទឹមគ្នានេះ ឯកឧត្តម អភិបាលខេត្តបានណែនាំឲ្យមន្ត្រីសុខាភិបាលនិងសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងសហការជាមួយក្រសួងសុខាភិបាល ដាក់ចេញនូវវិធានការនានាដើម្បីត្រៀមបង្ការនិងស្រាវជ្រាវករណីនេះ បើទោះបីជាមិនទាន់មានការបញ្ជាក់ជាផ្លូវការក៏ដោយ។ ដូចនេះ សូមសាធារណជនជាតិ និងអន្តរជាតិសូមមេត្តាជ្រាបជាព័ត៌មាន នឹងរង់ចាំការផ្សព្វផ្សាយជាផ្លូវការអំពីករណីនេះខាងភាគីជប៉ុន ក៏ដូចជាក្រសួងសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ៕

# ១៧. ដើមអម្ពិលៈមនុស្ស ៤៤នាក់ ត្រូវបានរកឃើញថា មានទាក់ទង ជាមួយជនជាតជប៉ុន ដែល រកឃើញថា មានជំងឺ Covid-19




ភ្នំពេញ៖ មនុស្ស ៤៤នាក់ ត្រូវបានរកឃើញថា មានទំនាក់ទំនងជិតដិត និងធ្លាប់មានទំនាក់ទំនង ជាមួយជនជាតិជប៉ុន រកឃើញមានផ្ទុកជំងឺកូវីដ១៩។ ក្នុងនោះ ៤នាក់ ជាជនដែលមានទំនាក់ទំនង ដោយផ្ទាល់ និង ៤០នាក់ទៀត ធ្លាប់មានទំនាក់ទំនង ។ នេះបើយោងតាមការឲ្យដឹងពី នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង CDC ។

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង CDC បានឲ្យដឹងថា ក្រោយពីទទួលបាន ព័ត៌មានថា ជនជាតិជប៉ុនមានផ្ទុកមេរោគ Covid-19, ក្រុមមន្ត្រីសុខាភិបាលថ្នាក់ជាតិ ថ្នាក់ខេត្ត និងអាជ្ញាធរខេត្តសៀមរាប កំពុងធ្វើការលើករណីនេះ ដោយតម្លាភាពបំផុត និងធ្វើការ ប្រកបដោយភាពត្រឹមត្រូវបំផុត ទៅតាមនីតិវិធីរបស់អង្គការ សុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រ។ យើងបានរកឃើញអ្នកប៉ះពាល់ផ្ទាល់ ៤នាក់ និង ប្រមាណ ៤០នាក់ ប៉ះពាល់ប្រយោល ដែលតំរូវ ឱ្យគាត់នៅ ដោយឡែកពីគេចំនួន១៤ថ្ងៃ និងតាមដានសុខភាព បើមានចេញរោគសញ្ញាត្រូវយកវត្ថុវិភាគជាបន្ទាន់ រហូតពេលនេះពួកគាត់ពុំទាន់មានរោគសញ្ញានៅឡើយទេ ។
សូមបញ្ជាក់ថាជនជាតិជប៉ុននេះ គាត់ជាអ្នកធុរកិច្ច គាត់បានធ្វើដំណើរ ជាបន្តបន្ទាប់ក្នុងរយៈពេលខ្លីពី ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសហ្វីលីពីន ប្រទេសកម្ពុជា បន្ទាប់មកទៅវៀតណាម និងត្រលប់ចូលប្រទេសជប៉ុនវិញហើយរកឃើញវិជ្ជមានCOVID-19 នៅទីនោះ។
រហូតដល់ម៉ោង ៤ល្ងាច ថ្ងៃទី៥ មីនា ២០២០ មិនទាន់កឃើញ ករណីថ្មីនៅឡើយទេ ។

សូមរំលឹកថា ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ បានបញ្ជាក់អំពីស្ថានភាពជនជាតិ ជប៉ុនម្នាក់ ដែលឆ្លងជំងឺកូរ៉ូណាថ្មី ឬ Covid-19 ដែលត្រូវបានពិនិត្យឃើញ ពេលចេញពីកម្ពុជា ទៅកាន់ប្រទេសជប៉ុន ដោយឆ្លងកាត់ ប្រទេសវៀតណាម។ នេះបើតាមលិខិតរបស់លោក អ៊ឹង រចនា អគ្គរាជទូតកម្ពុជាប្រចាំ នៅប្រទេសជប៉ុន បានធ្វើរបាយការណ៍ទៅកាន់ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា។

លោក អ៊ឹង រចនា អគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន បានបញ្ជាក់ថា បុរសជនជាតិជប៉ុនម្នាក់នោះ ត្រូវបានរកឃើញមានផ្ទុកជំងឺកូវីត១៩ ពេលទៅដល់អាកាសយានដ្ឋាន Chubu នៃទីក្រុង Nagoya ប្រទេសជប៉ុន នៅពេលគាត់ទៅពិភាក្សាជាមួយក្រុមមន្ត្រីចត្តាឡីស័ក ដោយសារគាត់ ពិបាកដកដង្ហើម។

បុរសរូបនេះ បានចាកចេញពីអាកាសយានដ្ឋានសៀមរាបម៉ោង២០:៥៧ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ ទៅកាន់អាកាសយានដ្ឋាន Tan Son Nhat ទីក្រុងហូជីមិញ រួចប្តូរជើងយន្តហោះហើយទៅកាន់ទីក្រុង Nagoya ប្រទេសជប៉ុន។ នេះបើតាមរបាយការណ៍។

បើតាមរបាយការណ៍ខាងលើនេះ មនុស្ស៥១នាក់ រួមទាំងបុគ្គលិក បម្រើលើយន្តហោះ ដែលធ្វើដំណើរមកពីសៀមរាប ទៅកាន់ប្រទេសវៀតណាម ជាមួយបុរសនោះ ត្រូវបានដាក់ឱ្យស្ថិតនៅដោយឡែក នៅទីក្រុងហូជីមិញ។

## ១៨. ដើមអម្ពិលៈពលករថៃ ១៩នាក់ ក្នុងចំណោម ១៨០នាក់ មានអាការៈគ្រុនក្តៅ ក្រោយត្រឡប់ពីកូរ៉េខាងត្បូង




បរទេស៖ ប៉ូលីសអន្តោប្រវេសន៍ថៃ បាននិយាយនៅថ្ងៃពុធថា ក្នុងចំណោមពលករថៃចំនួន ១៨០ នាក់ ដែលបានវិលត្រឡប់ មកពីប្រទេសកូរ៉េខាងត្បូង តាមរយៈអាកាសយានដ្ឋាន ក្នុងរយៈពេលបីថ្ងៃ គឺមាន ១៩ នាក់មានអាការៈក្តៅខ្លួន ប៉ុន្តែត្រូវបានធ្វើតេស្តិ៍អវិជ្ជមាន សម្រាប់មេរោគ Covid-19 ។

យោងតាមសារព័ត៌មាន Bangkok Post ចេញផ្សាយនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ បានឱ្យដឹងថា ជើងហោះហើររបស់ពួកគេ បានចុះចតនៅអាកាសយានដ្ឋានសុវណ្ណភូមិ នៅឌុនមឿង និងអាកាសយានដ្ឋាន ភូកេត។

ក្នុងចំណោមអ្នកមកដល់ចំនួន ១៨០ នាក់នោះ គឺមាន ១៩ នាក់ត្រូវបានរកឃើញថាមានគ្រុនក្តៅ ហើយត្រូវបានគេទុក ឱ្យនៅដាច់ដោយឡែក ដើម្បីត្រួតពិនិត្យ។ ពួកគេទាំងអស់ក្រោយមក បានធ្វើតេស្តិ៍អវិជ្ជមាន។ ចំណែកពលករ ១៦១ នាក់ផ្សេងទៀត ត្រូវបានអនុញ្ញាត ឱ្យទៅផ្ទះរបស់ពួកគេភ្លាមៗ ព្រោះគ្មានរោគសញ្ញាគ្រុនក្តៅ។

សូមជម្រាបថា ប្រទេសកូរ៉េខាងត្បូងបានរាយការណ៍ ពីករណីឆ្លងថ្មីនៃមេរោគ Covid-19 ចំនួន ៥១៦ ករណី នៅថ្ងៃពុធ ដោយនាំឱ្យចំនួនអ្នកឆ្លងសរុប របស់ប្រទេសកើនឡើងដល់ ៥,៣២៨ នាក់ ជាមួយនឹងការផ្ទុះឡើង នៅភាគអាគ្នេយ៍នៃទីក្រុង Daegu ដែលជាចំណុចផ្ទុះនៅទីនេះ ដែលបង្ហាញពីសញ្ញាតិចតួច នៃការធ្លាក់ចុះ។ ប្រែសម្រួល: ណៃ តុលា

# ១៩. ដើមអម្ពិលៈលោក គុណ ញឹម អះអាងថា ចំណូលពន្ធគយ ក្នុងខែកុម្ភៈធ្លាក់ចុះ ដោយសារជំងឺកូវីដ១៩

គេហទំព័រដើមអម្ពិល
ព័ត៌មានទាន់ហេតុការណ៍ ដោយៈលយ សុភាព
អូរ៉ូរ៉ា ស៊ីធី AURORA CITY (City Of Light)



សេវាឥណទាន
023 / 086 999 911
www.prasac.com.kh
រូបរាងប្រណិតរសជាតិទាញអារម្មណ៍
CAMBODIA
លោកអ្នកអាចទូទាត់ ប្រាក់រៀល នៅប្រទេសថៃ បានយ៉ាងងាយស្រួល ដោយស្កេនទូទាត់តាមរយៈ អេស៊ីលីដាទាន់ចិត្ត
You can pay in Khmer Riel at Thailand via ACLEDA ToanChet conveniently.
ACLEDA ToanChet
ប៊ូហ្វេអន្តរជាតិ
WORLD LUXURY RESTAURANT AWARDS WINNER

ព័ត៌មានជាតិ

## លោក គុណ ញឹម អះអាងថា ចំណូលពន្ធគយ ក្នុងខែកុម្ភៈធ្លាក់ចុះ ដោយសារជំងឺកូវីដ១៩ (វីដេអូ)

By PH104

Posted on March 5, 2020



ភ្នំពេញ ៖ លោក គុណ ញឹម អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានថ្លែងថា ក្នុងខែកុម្ភៈ ឆ្នាំ២០២០នេះ ចំណូលចូលអគ្គនាយកដ្ឋាន និងរដ្ឋាករកម្ពុជា មានការធ្លាក់ចុះបន្តិចដោយសារបញ្ហា ជំងឺកូរ៉ូណាប្រភេទថ្មី ឬហៅថាកូវីដ១៩។

ក្នុងសន្និសីទសារព័ត៌មាន ស្តីពី «វឌ្ឍនភាព និងទិសដៅការងាររបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ» នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២០ លោក គុណ ញឹម បានថ្លែងថា ចំណូលចូល អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានការធ្លាក់ចុះ កាលពីខែកុម្ភៈ កន្លងទៅដោយសារកត្តាពផ្សេងៗខ្លះ។

លោក គុណ ញឹម មានប្រសាសន៍ថា *«ខែមួយ (មករា) គួរលេខល្អ ខែពីរនេះ (កុម្ភៈ) ដោយសារប៉ះពាល់ខ្លាំង ពីការធ្លាក់ទេសចរណ៍ផង ហើយកូវីដ១៩ធ្លាក់ចុះ។ ខែពីរនេះចំណូលរបស់យើងទាបជាងផែនការបន្តិច ។ ឆ្នាំ២០២០ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ផែនការដែលកំណត់ដោយច្បាប់ហិរញ្ញវត្ថុ គឺត្រូវប្រមូលឲ្យបាន ២៩០០លានដុល្លារ ។ បើសិនគិតជាមធ្យមប្រចាំខែ យើងត្រូវប្រមូលឲ្យបានជិត ២៥០លានដុល្លារ សម្រាប់ខែមួយ យើងប្រមូលបាន ២៥៥ លានដុល្លារ មានន័យថា លើសផែនការបន្តិច ។ប៉ុន្តែសម្រាប់ខែពីរ យើងប្រមូលបានតែ២៣៥លានដុល្លារទេ ខ្វះបន្តិច»។*

បន្ថែមពីនេះ លោក គុណ ញឹម បញ្ជាក់ថា ភាគីពាក់ព័ន្ធបានរៀបចំច្រកសំខាន់ បន្ថែមទៀត ដើម្បីនាំចេញវត្ថុធាតុដើម ពីព្រោះវត្ថុធាតុដើមជាកត្តាអាទិភាពមុនគេ។
លោកថាបញ្ហាជំងឺកូវីដ១៩ ធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច ក្នុងសាកលលោកព្រមទាំង កម្ពុជាផងដែរ។

លោកបញ្ជាក់ថា *«យើងតាមដាន ជារៀងរាល់ថ្ងៃ ពីមួយថ្ងៃ ទៅមួយថ្ងៃ ពីមួយសប្តាហ៍ ទៅមួយសប្តាហ៍ ឃើញថា សញ្ញាល្អ ឡើងវិញហើយ ឃើញវត្ថុធាតុដើម ចាប់ផ្តើម មកវិញ ។ ហើយយើងត្រៀមថា បើសិនជាសម្រុកមកច្រើន យើងត្រៀមម៉ោងរដ្ឋបាល អាចធ្វើការដល់ម៉ោង១១ ឬ១២យប់។ហើយធ្វើយ៉ាងណា កជាល់មកដល់ភ្លាមៗ លើកដាក់ឡានរួចដឹកយកចេញពីកំពង់ផែ ទៅរោងចក្រ»* ។

ចំណែកលោក មាស សុខសេនសាន អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានឲ្យដឹងថា ឆ្នាំ២០២០នេះកម្ពុជា បានត្រៀមខ្លួនរួចជាសម្រេច ចំពោះហានិភ័យនានា ដែលអាចកើតមានឡើងបាន ជាពិសេស ហានិភ័យជាសាកល ព្រមទាំង ហានិភ័យផ្សេងៗទៀត ។

លោករំលឹកថា ក្នុងរយៈពេល២០ឆ្នាំ ចុងក្រោយនេះ កម្ពុជាសម្រេចបាន នូវកំណើន សេដ្ឋកិច្ច ក្នុងរង្វង់៧,៧% ដែលជាកំណើន មួយខ្ពស់បំផុត ព្រមទាំងធ្វើឲ្យកម្ពុជា សម្រេច បានៈជាប្រទេសចំណូល មធ្យមកម្រិតទាប តាំងពីឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ អត្រាអតិផរណា មធ្យម ប្រចាំឆ្នាំបន្តស្ថិតនៅកម្រិតទាប ហើយអត្រាប្តូរប្រាក់ នៅបន្តមានស្ថេរភាព ។
លោកបន្តថា នៅឆ្នាំ២០១៩ សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនខ្ពស់ ក្នុងអត្រា៧.១% ដែលធ្វើឲ្យផលិតផលសរុបក្នុងស្រុក សម្រាប់មនុស្សម្នាក់ៗកើនឡើងដល់ ១៩៧៩ដុល្លារ ក្នុង១ឆ្នាំ។ក្នុងនោះ អត្រា ភាពក្រីក្រត្រូវបានកាត់បន្ថយ មកនៅត្រឹមក្រោម១០% ។

លោកបន្ថែមថា បើពិនិត្យទៅលើទិន្នភាពកៀងគរថវិកាជាតិ និងគ្រប់គ្រងសម្បត្តិរដ្ឋ គិតពីឆ្នាំ២០១៣ដល់២០១៨ ចំណូលថវិការដ្ឋបានកើនឡើង ជាងពីរដង ចាប់ពី ជាង ២ពាន់លានដុល្លារ ដល់ជាង៤ពាន់លានដុល្លារ ។

ដោយៈ អេង ប៊ូនេង

## ២០. ដើមអម្ពិលៈប្រធានាធិបតីអ៊ីរ៉ង់ ៖ គូរ៉ូណាវីក រាលដាល ស្ទើរគ្រប់ខេត្ត ទាំងអស់របស់ខ្លួន




បរទេស ៖ នៅថ្ងៃពុធទី៤ ខែមិនានេះ បានឲ្យដឹងថា ប្រទេសអ៊ីរ៉ង់ កំពុងតែទទួលរងការវាយប្រហារ មិនអន់ជាងកូរ៉េខាងត្បូងនោះឡើយ មកដល់ពេលនេះ ដោយសារតែវាកំពុងរាតត្បាត ទៅដល់ស្ទើរគ្រប់ខេត្ត នៅទូទាំងប្រទេសទៅហើយ។

ការប្រកាស អះអាងបែបនេះ ត្រូវបានធ្វើឡើង ដោយលោកប្រធានាធិបតីអ៊ីរ៉ង់ ដោយផ្ទាល់តែម្តងនៅថ្ងៃពុធនេះ ។ យោងតាមការចេញផ្សាយ ដោយអ្នកសាយរបស់លោកប្រធានាធិបតី បានបញ្ជាក់ដែរថា សេចក្តីប្រកាសដែលត្រូវបានធ្វើឡើង ដោយលោកប្រធានាធិបតី នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ចុងក្រោយនេះ ។

គួរឲ្យដឹងដែរថា កាលពីថ្ងៃអង្គារ ម្សិលមិញនេះ លោករដ្ឋមន្ត្រីសុខាភិបាលអ៊ីរ៉ង់ បានបញ្ជាក់ថា មនុស្សស្លាប់បានកើនទៅដល់៩២នាក់ ហើយខណៈដែលអ្នកឆ្លងជំងឺ បានកើនទៅដល់២៩២២នាក់ ហើយផងដែរជាចំនួនដ៏ច្រើនបំផុត នៃប្រទេសដែលបានឆ្លងជំងឺនេះ ក្រៅតែពីប្រទេសចិន ។

ប្រែសម្រួល៖ស៊ុនលី

## ២១. ដើមអម្ពិលៈលោកអាបេ សង្ឃឹមថា នឹងអាចស្ទើយកកញ្ចប់ ប្រាក់បម្រុងចុងក្រោយ បង្អស់របស់រដ្ឋាភិបាល ដើម្បី




បរទេស ៖ ទីភ្នាក់ងារចិនស៊ិនហួ ចេញផ្សាយនៅថ្ងៃពុធទី៤ ខែមិនានេះ បានឲ្យដឹងថា នាយករដ្ឋមន្ត្រីជប៉ុន លោកស៊ីនហ្សូអាបេ នៅថ្ងៃនេះបានបង្ហាញជំហគួរឲ្យភ្ញាក់ផ្អើលថា លោកមានបំណង ប្រើប្រាស់នូវកញ្ចប់ប្រាក់ បម្រុងសារពើពន្ធឆ្នាំ ២០១៩ ចុងក្រោយបង្អស់ ដើម្បីប្រយុទ្ធប្រឆាំង នឹងការផ្ទុះឡើង នៃជំងឺរាតត្បាត COVID-19 ខណៈចំនួននៃការឆ្លង នៅតែបន្តកើនឡើង នៅក្នុងប្រទេសជប៉ុន។

នៅក្នុងសេចក្តីថ្លែង ការណ៍មួយ ដែលត្រូវបានធ្វើឡើង លោកអាបេ បានប្រាប់ទៅកាន់អង្គប្រជុំសភា របស់ប្រទេសជប៉ុន ថា យើងនឹងសម្រេចចិត្តថា តើត្រូវប្រើមូលនិធិទាំងអស់ ដែលនៅសេសសល់ទាំងនោះ នៅពេលយើងបញ្ចប់ការពិនិត្យ ទៅលើព័ត៌មានលម្អិត នៃកញ្ចប់ប្រាក់នៅត្រឹមថ្ងៃទី ១០ ខែមីនាខាងមុខនេះហើយយើង គឺចង់ប្រើទាំងអស់តែម្តង។

គួរឲ្យដឹងដែរថា មេដឹកនាំជប៉ុនរូបនេះ បាននិយាយគឺសំដៅទៅលើមូលនិធិបម្រុងចុងក្រោយ ដែលមានទំហំរហូតទៅដល់ចំនួន ២៧០ ពាន់លានយ៉េនឬប្រមាណជា២,៥ ពាន់លានដុល្លារអាមេរិកក្នុងពេលដែលការឆ្លងចំនួន ៦ ករណីទៀតត្រូវបានបញ្ជាក់ ដែលនាំឱ្យមានចំនួនសរុបដល់ ៩៨៦ នាក់និងចំនួនអ្នកស្លាប់បានកើនឡើងដល់ ១២ នាក់មកហើយនៅក្នុងប្រទេស។

ប្រែសម្រួល៖ស៊ុនលី

## ២២. ដើមអម្ពិលៈជប៉ុន នឹងលុបចោលពិធីរំលឹក ខួបនៃការស្លាប់ យ៉ាងច្រើន ដោយគ្រោះរញ្ជួយដី ដើម្បីទប់ស្កាត់ការ ឆ្លង




តូក្យូ៖ ទូរទស្សន៍សិង្ហបុរី Channel News Asia បានផ្សព្វផ្សាយព័ត៌មាន ឲ្យដឹងនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ថា ប្រព័ន្ធផ្សព្វផ្សាយរបស់ជប៉ុន បានរាយការណ៍មមកថា ប្រទេសជប៉ុន នឹងលុបចោលកម្មវិធីប្រារព្ធខួបនៃការស្លាប់យ៉ាងច្រើននៅក្នុងឆ្នាំ២០១១ ដោយគ្រោះរញ្ជួយដី ដែលបានបំផ្លិចបំផ្លាញ តំបន់ឆ្នេរ សមុទ្រ ប៉ែកឦសាន និងបង្កគ្រោះថ្នាក់អាក្រក់ នៅតំបន់នុយក្លេអ៊ែរ ហ្វូយកូស៊ីម៉ា (Fukushima)ហើយការប្រមូលផ្តុំគ្នានៅទីនោះ ខណៈដែល បង្កើនការប្រុងប្រយ័ត្នប្រឆាំង នឹងវីរុសកូរ៉ូណា ។

សេចក្តីរាយការណ៍បានឲ្យដឹងថា មនុស្សជាច្រើនចំនួន៧០០នាក់ ក្នុងនោះរាប់បញ្ចូលទាំងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងក្រុមអ្នកច្បាប់ បានរំពឹងថា នឹងចូលរួមក្នុងពិធីប្រារព្ធខួបថ្ងៃទី១១ មីនា នៅក្រុងតូក្យូ ។ រដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រីជប៉ុន ស៊ិនហ្សូ អាបេ នឹងធ្វើសេចក្តីសម្រេចចិត្តជាផ្លូវការ ដើម្បីអបអរសាទរនៅក្នុងព្រឹត្តិការណ៍ នៅពេលដែលគណៈរដ្ឋមន្ត្រីរបស់គាត់នឹងបើកកិច្ចប្រជុំនៅថ្ងៃសុក្រ ។

គួររំលឹកថា កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ មានគ្រោះរញ្ជួយដីដ៏ខ្លាំងកម្រិត៩រិចទ័រ បានបង្កជារលកយក្សស៊ូណាមិ ដែលបោកបក់មកលើសហគមន៍អ្នករស់នៅតាមឆ្នេរសមុទ្រ និងបានបង្កការខូចខាតដល់រោងចក្រថាមពលនុយក្លេអ៊ែរ ហ្វូយកូស៊ីម៉ា ។

ប្រែសម្រួលដោយ៖ ម៉ៅ បុប្ផាមករា

## ២៣. ដើមអម្ពិលៈនេះរដ្ឋមន្ត្រី ការពារជាតិ របស់អាមេរិក និងចិន ពិភាក្សាគ្នា លើបញ្ហាកូរ៉ូណា




ប៉េកាំង ៖ នៅថ្ងៃពុធទី៤ ខែមីនានេះ ក្រសួងការពារជាតិចិន បាននិយាយថា រដ្ឋមន្ត្រី ការពារជាតិចិន លោក Wei Fenghe បានពិភាក្សាអំពីស្ថានភាព មេរោគឆ្លងនៅក្នុងប្រទេសចិន ជាមួយរដ្ឋមន្ត្រីក្រសួង ការពារជាតិ សហរដ្ឋអាមេរិក លោក Mark Esper ។

កិច្ចពិភាក្សា ត្រូវបានធ្វើឡើង នៅព្រឹកថ្ងៃពុធនេះ តែម្តងដោយក្នុងនោះ លោកWei បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ស្ថានភាពរបស់ជំងឺរាតត្បាតកូរ៉ូណា នៅក្នុងប្រទេសចិន កំពុងតែបន្តមានភាពវិជ្ជមាន និងល្អប្រសើរឡើងវិញ ហើយលោកបន្ថែមថា ភាគីអាមេរិកនិងចិន គួរតែព្យាយាមដោះស្រាយបញ្ហា មិនត្រូវរំរូខ្មាលើកិច្ចពិភាក្សា និងប្រឹក្សាយោបល់ផងដែរ។

ជាការឆ្លើយតប លោកEsper បានបញ្ជាក់អំពីការតាំងចិត្ត របស់ខ្លួនក្នុងការធ្វើការជម្រុញ ឲ្យមានកិច្ចពិភាក្សា កាន់តែជិតស្និទ្ធឡើង រវាងប្រទេសទាំងពីរ ជាពិសេសលើវិស័យយោធា និងក៏ដូចជាការត្រួតពិនិត្យ ការការពារលើការងារ ផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការ រវាងខ្មានិងខ្មាផង។

ប្រែសម្រួល៖ស៊ុនលី

# ២៤. ដើមអម្ពិលៈ ការឆ្លងវីរុសកូរ៉ូណា នៅកូរ៉េខាងត្បូងកើនឡើង ឆាប់រហ័ស ភាគច្រើនជាមនុស្សចាស់ ដែល មានបញ្ហា




សេអ៊ូល៖ អាជ្ញាធរសុខភាពបានឲ្យដឹងថា ជនរងគ្រោះភាគច្រើន នៃវីរុសឆ្លងកូរ៉ូណា រាលដាលយ៉ាងឆាប់រហ័សនៅ ទូទាំងប្រទេសកូរ៉េខាងត្បូង គឺជាមនុស្សវ័យចំណាស់ ដែលមានបញ្ហាសុខភាព និងការយកចិត្តទុកដាក់ ពិសេសដើម្បីកាត់បន្ថយ ការស្លាប់ដែលទាក់ទងនឹងវីរុស។

យោងតាមមជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺកូរ៉េ (KCDC) បានឱ្យដឹងថា ករណីនៃជំងឺ កូវីដ-១៩ បានបញ្ជាក់កាលពីថ្ងៃអង្គារថា ចំនួនអ្នកឆ្លងសរុបរបស់ប្រទេសបានកើនឡើងដល់ ៥,១៨៦ នាក់គិតត្រឹមម៉ោង ៤ រសៀលដោយមានមនុស្សស្លាប់ ៣១នាក់។ អ្នកស្លាប់ ៣នាក់បន្ថែមទៀត ត្រូវបានរាយការណ៍នៅថ្ងៃអង្គារនេះ នៅភាគអាគ្នេយ៍ទីក្រុងដេហ្គូ ដែលជាចំណុចកណ្តាលនៃការផ្ទុះវីរុសនៅទីនេះ។

មន្ត្រីបានឲ្យដឹងថាការស្លាប់ ១០នាក់ចុងក្រោយ បានកើតឡើងក្នុងពេល កំពុងព្យាបាលនៅមន្ទីរពេទ្យក្នុងទីក្រុង Daegu ឬនៅជុំវិញខេត្ត North Gyeongsang ដោយជនរងគ្រោះទាំងអស់មានជំងឺស្រាលហើយមានអាយុពី ៦០ ទៅ ៨០ឆ្នាំ។

ដោយ ឈូក បូរ៉ា

# ២៥. ដើមអម្ពិលៈលោក ទៀ សីហា ៖ ជនជាតជប៉ុន ដែលវៀតណាមរកឃើញ កូវីដ១៩នោះ ពេលមិនទាន់ចេញពីកម្ពុជា ពុំមានរោគសញ្ញាឆ្លងឡើយ




ភ្នំពេញ ៖ លោក ទៀ សីហា អភិបាលខេត្តសៀមរាប បានអះអាងថា ជនជាតិជប៉ុនម្នាក់ ដែលវៀតណាមរកឃើញ មានផ្ទុកវីរុសកូរ៉ូណាថ្មី បន្ទាប់ពីចាកចេញពីព្រលាន យន្តហោះខេត្តសៀមរាប ទៅដល់ព្រលានយន្តហោះ ក្រុងហូជីមិញនោះ មុនចេញដំណើរពីកម្ពុជា ពុំមានរោគសញ្ញាកើតជំងឺ COVID-19 ឡើយ ហើយភាគីជប៉ុន ក៏មិនទាន់បញ្ជាក់ជាផ្លូវការថា ជនជាតិជប៉ុនរូបនោះ ឆ្លងជំងឺ COVID-19 នៃរ។

កាលពីពេលថ្មីៗនេះ សារព័ត៌មានវៀតណាមបានចុះផ្សាយថា ជនជាតិជប៉ុនម្នាក់បានឆ្លងជំងឺ COVID-19 បន្ទាប់ពីហោះចេញពីព្រលានយន្តហោះអន្តរជាតិសៀមរាប ឆ្លងកាត់ព្រលានយន្តហោះ ទីក្រុងហូជីមិញ ប្រទេសវៀតណាម រួចបន្តដំណើរទៅប្រទេសជប៉ុន ។

តាមរយៈបណ្ដាញសង្គមហ្វេសប៊ុក រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី៥ មីនានេះ លោក ទៀ សីហា បានមានប្រសាសន៍ថា ជនជាតិជប៉ុនរូបនេះ គឺគាត់ជាអ្នករស់នៅ និងប្រកបអាជីវកម្មនៅក្នុងខេត្តសៀមរាប មិនមែនមកដំណើរកំសាន្ត លក្ខណៈទេសចរណ៍នោះទេ។

លោកអភិបាលខេត្តបញ្ជាក់ថា «អាជ្ញាធរខេត្តបានយកចិត្តទុកដាក់ខ្ពស់ លើបញ្ហានេះដោយបានសហការ ជាមួយនឹងកុងស៊ុលជប៉ុន ប្រចាំខេត្តសៀមរាប មន្ទីរ និងក្រសួងសុខាភិបាលសុខាភិបាល ។ តាមការបញ្ជាក់របស់មន្ត្រីសុខាភិបាលខេត្ត និងភាគីកុងស៊ុលជប៉ុន ប្រចាំខេត្តបានបញ្ជាក់ថា មុនចេញដំណើរការពិនិត្យសុខភាព ជនជាតិជប៉ុនរូបនេះ ពុំមានរោគសញ្ញាកើតជំងឺ COVID-19នោះឡើយ» ។

លោកអភិបាលខេត្តបន្ថែមថា ម្យ៉ាងវិញទៀត ភាគីជប៉ុនបានបញ្ជាក់ថា ក្រសួងសុខាភិបាលជប៉ុន ពុំទាន់បានជូនដំណឹងជាផ្លូវការ ថាជនជាតិជប៉ុនរូបនេះមានឆ្លងនឹងកើតជំងឺ COVID-19 នៅឡើយ។ ទន្ទឹមនេះ លោកអភិបាលខេត្ត ក៏បានណែនាំឲ្យមន្ត្រីសុខាភិបាល និងសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងសហការជាមួយ ក្រសួងសុខាភិបាលដាក់ចេញនូវ វិធានការនានាដើម្បីត្រៀមបង្ការ និងស្រាវជ្រាវករណីនេះ បើទោះបីជាមិនទាន់មាន ការបញ្ជាក់ជាផ្លូវការក៏ដោយ ៕

ដោយ៖ ឌា ដា